# ជំនួយសុខភាពផ្លូវចិត្ត

## ភាគ ៤



រៀបរៀងដោយ

សាមណេរ ធម្មាលង្ការោ ចាន់ សុជន

រក្សាសិទ្ធិ

Copyright © 2008

# នមស្សការព្រះត្រៃរតន៍

➩➩ ⚜ ⇦⇦

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ចំពោះព្រះសម្មា-សម្ពុទ្ធអង្គនោះ ដែលព្រះអង្គប្រៀបដូចអ្នកកាន់ប្រទីបបំភ្លឺលោកនេះ ។

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ចំពោះព្រះសទ្ធម្ម ដែលព្រះសទ្ធម្មនោះ ប្រៀបដូចប្រទីបបំភ្លឺលោកនេះ ឲ្យភ្លឺស្វាងឡើង។

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ចំពោះព្រះសង្ឃ ដែលព្រះសង្ឃនោះ ប្រៀបដូចលោកនេះ ដែលភ្លឺស្វាងចាកងងឹត ។

ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឭក ស្មើដោយត្បូងរបស់ខ្ញុំព្រះករុណា ។

ដោយអានុភាពនៃកិរិយាមនស្សការថ្វាយបង្គំ សូមឲ្យកម្ចាត់បង់នូវឧបទ្រពទាំងឡាយទាំងពួង ។

# ខ
# បុព្វកថា

ព្រះសម្មសម្ពុទ្ធ ព្រះអង្គទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយ ថា ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ! ឥឡូវនេះ តថាគត ប្រាប់អ្នកទាំងឡាយឲ្យដឹង ! សង្ខារទាំងឡាយមាន សេចក្តី សាបសូន្យជាធម្មតា អ្នកទាំងឡាយ ចូរញ៉ាំងកិច្ច ទាំងពួង ឲ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ ។ នេះជាបច្ឆឹម-វាចារបស់ព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គសម្តែង នៅពេល ដែលព្រះអង្គទៀបនឹងបរិនិព្វាន ដោយអនុបាទិសេស និព្វាន ។

ពុទ្ធបរិស័ទយើង មានចំណុចខ្វះខាតដោយអន្លើ ដោយសារតែមិនបានសិក្សា រៀនសូត្រព្រះធម៌ឲ្យបាន ជម្រៅ ។ តាមពិត ការដែលបដិបត្តិខ្លួន ឲ្យជាឧបាសក ឧបាសិកា ឬ ពុទ្ធបរិស័ទ ឲ្យពិតប្រាកដនោះ មិនមែននៅ ត្រង់សណ្ឋានទ្រង់ទ្រាយខាងក្រៅនោះទេ គឺនៅក្នុងចិត្ត សន្តាន ដែលបានទទួលយកព្រះធម៌មកដាក់ក្នុងខ្លួន ឲ្យ បានជ្រួតជ្រាបយល់ច្បាស់លាស់អំពីហេតុផល ។

ដូច្នេះ ពុទ្ធបរិស័ទគប្បីសិក្សា ស្តាប់ ពិចារណា ស្វែងយល់ អំពីសេចក្តីដែលមាននៅក្នុងព្រះពុទ្ធសាសនា ដោយការត្រាស់ដឹង និងការប្រកាសសម្តែងរបស់ព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ។

ស្រីលង្កា,ថ្ងៃទី ១៥ កើត ខែមាឃ ព.ស. ២៥៥១

សាមណេរ ធម្មាលង្ការោ **ចាន់ សុជន**

ឃ

# ឧទ្ទិសកថា

➪➪ ⚜ ⬅⬅

កុសលចេតនា របស់ខ្ញុំព្រះករុណា អាត្មាភាព ដែលបានរៀបរៀងសៀវភៅ **ជំនួយសុខភាពផ្លូវចិត្ត ភាគ ៤** នេះ ខ្ញុំព្រះករុណា អាត្មាភាព សូមគោរពដឹងគុណចំពោះព្រះរតនត្រ័យ និងមាតាបិតា ដែលបានផ្ដល់កំណើតឲ្យខ្ញុំ ។

ម្យ៉ាងវិញទៀត សៀវភៅនេះ ប្រសូតចេញពីការសិក្សារៀនសូត្រ ព្រះធម៌ ព្រះវិន័យ របស់ព្រះជិនស្រី ដែលព្រះអង្គទ្រង់ត្រាស់សម្ដែងហើយ ។ ជាពិសេសជាក់ស្ដែងក្នុងបច្ចុប្បន្ននេះ គឺបានទទួលការសិក្សារៀនសូត្រស្ដាប់ ពីសំណាក់លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។

ដូច្នេះ ខ្ញុំសូមគោរព ប្រគេនបុណ្យ និងជូនបុណ្យចំពោះអ្នកមានគុណ ដូចមានឈ្មោះខាងក្រោមនេះ ៖

-លោកឪពុក ចាន់ សាមឿន

-អ្នកម្ដាយ ឃួន សាខន

-ព្រះឧបជ្ឈាយ៍ កណ្ហវណ្ណោ ប៉ុក វុន

-លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស

-ព្រះគ្រូធម្មាចារ្យ សោភណត្ថេរោ សោម សុភាព

-លោកគ្រូធម្មាចារ្យ រស់ សុផាត

-ព្រមទាំងជូនបុណ្យ ចំពោះសព្វសត្វទាំងឡាយក្នុងសង្សារវដ្ដ សូមជ្រះថ្លា ត្រេកអរអនុមោទនា ឲ្យបានគ្រប់ៗគ្នា ។

*សូមអនុមោទនា !!!*

# សារប័ណ្ណ


| អត្ថបទធម៌ | ទំព័រ |
| --- | --- |
| -នមស្សការព្រះត្រៃរតន៍.......................... | ក |
| -បុព្វកថា.............................................. | ខ |
| -ឧទ្ទិសកថា.......................................... | ឃ |

**រូបាវចរចិត្ត ១៥ ដួង**

រូបាវចរកុសលចិត្ត ៥ ដួង

| | |
| --- | --- |
| **រូបាវចរកុសលចិត្តដួងទី ១**.................... | ១ |
| ធម៌អប់រំចិត្តស្តីអំពី សេចក្តីផ្លូវផង់នៃ ព្រះនិព្វាន........................................... | ២ |
| **រូបាវចរកុសលចិត្តដួងទី ២**.................. | ៤ |
| ធម៌អប់រំចិត្តស្តីអំពី ពាក្យថាព្រះនិព្វាន..... | ៥ |
| **រូបាវចរកុសលចិត្តដួងទី ៣**.................... | ៧ |
| ធម៌អប់រំចិត្តស្តីអំពី កាមគុណ ៥ ប្រការ... | ៨ |
| **រូបាវចរកុសលចិត្តដួងទី ៤**.................... | ១០ |
| ធម៌អប់រំចិត្តស្តីអំពី ការឧបមានៃ កាមគុណ ៥ ប្រការ............................. | ១១ |

**រូបាវចរកុសលចិត្តជួនទី ៥**..................... ១៣

ធម៌អប់រំចិត្តស្តីអំពីឱវាទដែលមានឧបមា

ដូចជារណារ........................................ ១៤

**រូបាវចរវិបាកចិត្ត ៥ ជួន**

**រូបាវចរវិបាកចិត្ត ជួនទី ១**..................... ១៦

ធម៌អប់រំចិត្តស្តីអំពីឧទាននៃព្រះសម្ពុទ្ធ..... ១៧

**រូបាវចរវិបាកចិត្ត ជួនទី ២**.................... ១៨

ធម៌អប់រំចិត្តស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ.... ១៩

**រូបាវចរវិបាកចិត្ត ជួនទី ៣**.................... ២០

ធម៌អប់រំចិត្តស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ.... ២១

**រូបាវចរវិបាកចិត្ត ជួនទី ៤**..................... ២២

ធម៌អប់រំចិត្តស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ.... ២៤

**រូបាវចរវិបាកចិត្ត ជួនទី ៥**.................... ២៥

ធម៌អប់រំចិត្តស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ.... ២៦

**រូបាវចរកិរិយាចិត្ត ៥ ជួន**

**រូបាវចរកិរិយាចិត្ត ជួនទី ១**..................... ២៧

ធម៌អប់រំចិត្តស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ.... ២៨

**រូបាវចរកិរិយាចិត្ត ដួងទី ២**.................... ២៩

ធម៌អប់រំចិត្តស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ... ៣០

**រូបាវចរកិរិយាចិត្ត ដួងទី ៣**.................... ៣១

ធម៌អប់រំចិត្តស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ... ៣២

**រូបាវចរកិរិយាចិត្ត ដួងទី ៤**.................... ៣៣

ធម៌អប់រំចិត្តស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ... ៣៤

**រូបាវចរកិរិយាចិត្ត ដួងទី ៥**.................... ៣៥

ធម៌អប់រំចិត្តស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ... ៣៦

**អរូបាវចរចិត្ត ១២ ដួង**

**រូបាវចរកុសលចិត្ត ៤ ដួង**

**រូបាវចរកុសលចិត្ត ដួងទី ១**.................... ៣៧

ធម៌អប់ចិត្តស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ..... ៣៨

**រូបាវចរកុសលចិត្ត ដួងទី ២**.................... ៣៩

ធម៌អប់រំចិត្តស្តីអំពីឧទាននៃព្រះសម្ពុទ្ធ.... ៤០

**រូបាវចរកុសលចិត្ត ដួងទី ៣**.................... ៤២

ធម៌អប់រំចិត្តស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ... ៤៣

**រូបាវចរកុសលចិត្ត ដួងទី ៤**.................... ៤៤

ធម៌អប់ចិត្តស្តីអំពីឧទាននៃព្រះសម្ពុទ្ធ...... ៤៥

## អរូបាវចរវិបាកចិត្ត ៤ ដួង


**អរូបាវចរវិបាកចិត្ត ដួងទី ១**................. ៤៦

ធម៌អប់រំចិត្តស្ដីអំពី ឧទាននៃព្រះសម្ពុទ្ធ.... ៤៧

**អរូបាវចរវិបាកចិត្ត ដួងទី ២**................. ៤៨

ធម៌អប់រំចិត្តស្ដីអំពី ឧទាននៃព្រះសម្ពុទ្ធ.... ៤៩

**អរូបាវចរវិបាកចិត្ត ដួងទី ៣**................. ៥០

ធម៌អប់រំចិត្តស្ដីអំពី ឧទាននៃព្រះសម្ពុទ្ធ.... ៥១

**អរូបាវចរវិបាកចិត្ត ដួងទី ៤**................. ៥២

ធម៌អប់រំចិត្តស្ដីអំពី ឧទាននៃព្រះសម្ពុទ្ធ.... ៥៣


## អរូបាវចរកិរិយាចិត្ត ៤ ដួង


**អរូបាវចរកិរិយាចិត្ត ដួងទី ១**................. ៥៤

ធម៌អប់រំចិត្តស្ដីអំពី ជនមានចិត្តស្លុងទៅ
កាន់ព្រះនិព្វាន...................................... ៥៥

**អរូបាវចរកិរិយាចិត្ត ដួងទី ២**................. ៥៦

ធម៌អប់រំចិត្តស្ដីអំពី ពាក្យថា មិនលិចចុះ... ៥៧

**អរូបាវចរកិរិយាចិត្ត ដួងទី ៣**................. ៥៨

ធម៌អប់រំចិត្តស្ដីអំពីការលូតលាស់
និងការមិនលូតលាស់ក្នុងធម៌វិន័យ......... ៥៩

**អរូបាវចរកិរិយាចិត្ត ដួងទី ៤**.................. ៦០

ធម៌អប់រំចិត្តស្តីអំពី ការយល់របស់បុគ្គលអ្នក
មិនសាបសូន្យ...................................... ៦១

**បទសិក្សាទី ១**

ស្តីអំពី សិក្ខាបទ ៣ យ៉ាង....................... ៦២

**បទសិក្សាទី ២**

ស្តីអំពីពាក្យថា ព្រះមានព្រះភាគ............ ៦៤

**បទសិក្សាទី ៣**

ស្តីអំពី សរ គឺ រាគៈ............................. ៦៨

**បទសិក្សាទី ៤**

ស្តីអំពី រគឺ ទោសៈ................................ ៦៩

**បទសិក្សាទី ៥**

ស្តីអំពី សរ គឺ មោហៈ......................... ៧០

**បទសិក្សាទី ៦**

ស្តីអំពី សរគឺ មានៈ.............................. ៧១

**បទសិក្សាទី ៧** ស្តីអំពី សរ គឺ ទិដ្ឋិ........... ៧២

**បទសិក្សាទី ៨** ស្តីអំពីសរគឺ សេចក្តី សោក. ៧៣

**បទសិក្សាទី ៩** ស្តីអំពី សរគឺសេចក្តីសង្ស័យ. ៧៤

-**បទសិក្ខាទី ១០** ស្ដីអំពី ខន្ធមិនគួរដល់ការ
ត្រេកអរ................................................ ៧៥

## សមថកម្មដ្ឋាន ៤០

ពួកទី ១ កសិណ ១០ គឺ.......................... ៧៦
ពួកទី ២ អសុភ (របស់មិនស្អាត់) ១០ គឺ........ ៧៧
ពួកទី ៣ អនុស្សតិ ១០................................ ៧៨
ពួកទី ៤ ព្រហ្មវិហារធម៌ ៤ គឺ................... ៧៩
ពួកទី ៥ បដិក្កូលសញ្ញា ១.......................... ៧៩
ពួកទី ៦ ធាតុវវដ្ឋាន ១................................ ៧៩
ពួកទី ៧ អរូបជ្ឈាន ៤................................ ៨០

## កម្មដ្ឋាន ៤០ ចែកជា ៣ ប្រភេទ

១-សប្បាយបភេទ..................................... ៨០
២-ភាវនាបភេទ......................................... ៨១
៣-អារម្មណបភេទ.................................... ៨៣

# រូបាវចរចិត្ត ១៥ ដួង

## *រូបាវចរកុសលចិត្ត ៥ ដួង*

### រូបាវចរកុសលចិត្ត ដួងទី ១

*១-វិតក្កវិចារបីតិសុខឯកគ្គតាសហិតំ បឋមជ្ឈាន-កុសលចិត្តំ ។*

បឋមជ្ឈានកុសលចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ៥ គឺ វិតក្កៈ វីចារៈ បីតិ សុខ ឯកគ្គតា ។

*មានចេតសិកប្រកប ៣៥*

| | |
|---|---|
| -អញ្ញាសមាចេតសិក | ១៣ |
| -សោភណចេតសិក | ២២ (វៀរវិរតិ ៣ ) ។ |

*ចែកជាខន្ធ*

| | |
|---|---|
| -វេទនាចេតសិក | ជាវេទនាខន្ធ |
| -សញ្ញាចេតសិក | ជាសញ្ញាខន្ធ |
| -ចេតសិក ៣៣ | ជាសង្ខារក្ខន្ធ |
| -រូបាវចរកុសលចិត្ត | ជាវិញ្ញាណក្ខន្ធ ។ |

*ចែកជាធាតុ*

-ចេតសិក ៣៥ ជាធម្មធាតុ

-រូបាវចរកុសលចិត្ត ជាមនោវិញ្ញាណធាតុ ។

*ចែកជាអាយតនៈ*

-ចេតសិក ៣៥ ជាធម្មាយតន

-រូបាវចរកុសលចិត្ត ជាមនាយតន ។

*ចែកជាសច្ចៈ*

-ចេតសិក ៣៥ ជាទុក្ខសច្ច

-រូបាវចរកុសលចិត្ត ជាទុក្ខសច្ច ។

## ធម៌អប់រំចិត្ត

ស្តីអំពី សេចក្តីផូរផង់នៃព្រះនិព្វាន

( ស្រង់ចាក សំយុត្តនិកាយ បិដកលេខ ៣៧ ទំព័រ ២១២ )

បណ្តាមនុស្សទាំងឡាយ ជនទាំងឡាយឯណា ដល់នូវត្រើយគឺព្រះនិព្វាន ជនទាំងឡាយនោះ មានតិចតួចទេ សត្វក្រៅពីនេះ សសៀរទៅតាមត្រើយ គឺវដ្តៈ ។ ពួកជនណាប្រព្រឹត្តតាមធម៌ក្នុងធម៌ ដែលព្រះតថាគតសម្តែងប្រាប់ប្រពៃហើយ ពួកជននោះនឹងឆ្លងផុតទីកន្លែងរបស់មច្ចុ ដែលគេឆ្លងដោយលំបាកពេក ហើយដល់នូវត្រើយគឺ ព្រះនិព្វានបាន ។

បណ្ឌិតលះបង់នូវធម៌ខ្មៅ ហើយចម្រើននូវធម៌ស ចេញចាកអាល័យអាស្រ័យព្រះនិព្វាន ដែលគ្មានសេចក្តីអាល័យ ហើយគម្បីលះបង់កាមទាំងឡាយ ជាអ្នកឥតមានកង្វល់ប្រាថ្នានូវសេចក្តីត្រេកអរចំពោះសេចក្តីស្ងប់ស្ងាត់ ដែលសត្វត្រេកអរបានដោយកម្រនោះ បណ្ឌិតត្រូវធ្វើខ្លួនឱ្យផូរផង់ ចាកសេចក្តីសៅហ្មងនៃចិត្ត ។ ពួកជនណា បានចម្រើនចិត្តដោយប្រពៃក្នុងសម្ពោជ្ឈង្គទាំងឡាយ ហើយមិនបានប្រកាន់មាំ ត្រេកអរក្នុងការលះបង់ សេចក្តីប្រកាន់ពួកជននោះ រមែងអស់អាសវៈមានសេចក្តីរុងរឿង បរិព្វានហើយក្នុង លោក ។

## រូបាវចរកុសលចិត្តដួងទី ២

*២-វិចារបីតិសុខឯកគ្គតាសហិតំ ទុតិយជ្ឈានកុសលចិត្តំ ។*

ទុតិយជ្ឈានកុសលចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ៤ គឺ វិចារៈ បីតិ សុខៈ ឯកគ្គតា ។

*មានចេតសិកប្រកប ៣៤*

-អញ្ញាសមាចេតសិក ១២ ( វៀរ វិតក្កៈ )

-សោភណចេតសិក ២២ (វៀរវិរតិ ៣ ) ។

*ចែកជាខន្ធ*

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣២ ជាសង្ខារក្ខន្ធ

-រូបាវចរកុសលចិត្ត ជាវិញ្ញាណក្ខន្ធ ។

*ចែកជាធាតុ*

-ចេតសិក ៣៤ ជាធម្មធាតុ

-រូបាវចរកុសលចិត្ត ជាមនោវិញ្ញាណធាតុ ។

## ចែកជាអាយតន

| | |
|---|---|
| -ចេតសិក ៣៤ | ជាធម្មាយតន |
| -រូបាវចរកុសលចិត្ត | ជាមនាយតន ។ |

## ចែកជាសច្ច

| | |
|---|---|
| -ចេតសិក ៣៤ | ជាទុក្ខសច្ច |
| -រូបាវចរកុសលចិត្ត | ជាទុក្ខសច្ច ។ |

# ធម៌អប់រំចិត្ត

## ស្តីអំពី ពាក្យថាព្រះនិព្វាន

( ស្រង់ចាក សំយុត្តនិកាយ បិដកលេខ ៣៦ ទំព័រ ១០៨ )

សម័យមួយ ព្រះសារីបត្តដ៏មានអាយុគង់នៅក្នុងនាលគ្រាម នាដែនមគធៈ ។ គ្រានោះឯង បរិព្វាជកឈ្មោះជម្ពុខាទកបានចូលទៅរកព្រះសារីបត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ពោលសំណេះសំណាលជាមួយនឹង ព្រះសារីបុត្តដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះជម្ពុ-

ខាទកបរិព្វាជក អង្គុយក្នុងទីដ៏សមគួរហើយ ក៏និយាយនឹងព្រះសារីបុត្តដ៏មានអាយុដូច្នេះថា ម្នាលអាវុសោ សារីបុត្ត គេតែងនិយាយថា **និព្វាន និព្វាន** ម្នាលអាវុសោ ដូចម្តេចហ្ន៎ ហៅថានិព្វាន ?

ព្រះសារីបុត្តតបថា ម្នាលអាវុសោ សភាវៈដែលជាទី អស់ទៅនៃរាគៈ អស់ ទៅនៃទោសៈ អស់ទៅនៃមោហៈ នេះ ហៅថានិព្វាន ។

ជម្ពុខាទកបរិព្វាជក សួរបន្តទៀតថា ម្នាលអាវុសោ ចុះជាមគ្គ និងជាបដិបទា ដែលប្រព្រឹត្តទៅដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាននុ៎ះមានដែរឬ ?

ព្រះសារីបត្តឆ្លើយថា ម្នាលអាវុសោ មគ្គ និងបដិបទា ដែលប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននុ៎ះមានដែរ ។

ព្រះសារីបុត្តឆ្លើយថា ម្នាលអាវុសោ មគ្គប្រកបដោយអង្គ ៨ នោះ គឺ **សម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១** ។ ម្នាលអាវុសោ នេះហៅថា **មគ្គ** នេះហៅថា **បដិបទា** ដែលប្រព្រឹត្តទៅ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន នុ៎ះបាន ។ ជម្ពុខាទកបរិព្វាជកពោលថា ម្នាលអាវុសោសារីបុត្ត បើដូច្នេះបុគ្គលគួរ (តម្កល់ចិត្ត) ក្នុងអប្បមាទធម៌ ។

## **រូបាវចរកុសលចិត្តដួងទី ៣**

*៣-បីតិសុខឯកគ្គតាសហិតំ តតិយជ្ឈានកុសលចិត្តំ ។*

តតិយជ្ឈានកុសលចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ៣ គឺ បីតិ សុខៈ ឯកគ្គតា ។

*មានចេតសិកប្រកប ៣៣*

| | |
|---|---|
| -អញ្ញាសមាចេតសិក | ១១ ( វៀរ វិតក្កៈ វិចារៈ ) |
| -សោភណចេតសិក | ២២ (វៀរវិរតិ ៣ ) ។ |

*ចែកជាខន្ធ*

| | |
|---|---|
| - វេទនាចេតសិក | ជាវេទនាខន្ធ |
| - សញ្ញាចេតសិក | ជាសញ្ញាខន្ធ |
| - ចេតសិក ៣១ | ជាសង្ខារក្ខន្ធ |
| - រូបាវចរកុសលចិត្ត | ជាវិញ្ញាណក្ខន្ធ ។ |

*ចែកជាធាតុ*

| | |
|---|---|
| - ចេតសិក ៣៣ | ជាធម្មធាតុ |
| - រូបាវចរកុសលចិត្ត | ជាមនោវិញ្ញាណធាតុ ។ |

*ចែកជាអាយតន*

| | |
|---|---|
| - ចេតសិក ៣៣ | ជាធម្មាយតន |
| - រូបាវចរកុសលចិត្ត | ជាមនាយតន ។ |

## ចែកជាសច្ច

- ចេតសិក ៣៣ ជាទុក្ខសច្ច
- រូបាវចរកុសលចិត្ត ជាទុក្ខសច្ច ។

# ធម៌អប់រំចិត្ត

## ស្ដីអំពី កាមគុណ ៥ ប្រការ

( ស្រង់ចាក មជ្ឈិមនិកាយ បិដកលេខ ២១ ទំព័រ ១៦៣ )

ម្នាលភិក្ខុទាំងឡាយ កាមគុណនេះមាន ៥ ប្រការ កាមគុណ ៥ ប្រការ តើដូចម្ដេច ? គឺរូបទាំងឡាយ ដែលគប្បីឃើញដោយចក្ខុជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត មានសភាព គួរឱ្យស្រលាញ់ ប្រកបដោយកាមគួររីករាយ ១ សម្លេងដែលគប្បី ដឹងបានដោយសោតៈ ជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត មានសភាពគួរឱ្យស្រលាញ់ ប្រកបដោយកាមគួររីករាយ ១ ក្លិនគប្បីដឹងបានដោយឃានៈ ជាទីប្រាថ្នា ជាទីពេញចិត្ត មានសភាពគួរឲ្យស្រលាញ់ប្រកប

គួររីករាយ ១ រសដែលគប្បីដឹងបានដោយជីវ្ហា ជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត មានសភាពគួរឱ្យស្រលាញ់ ប្រកបដោយកាមគួររីករាយ ១ ផោដ្ឋព្វៈ «របស់ដែលជាគ្រឿងប៉ះពាល់ដោយកាយបសាទមានរឹង ទន់ជាដើម » ដែលគប្បីដឹងបានដោយកាយជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត មានសភាពគួរឱ្យស្រលាញ់ ប្រកបដោយកាមគួរត្រេកត្រអាល ១ ម្នាលភិក្ខុទាំងឡាយនេះឯង កាមគុណមាន ៥ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ សមណៈ ឬ ព្រាហ្មណ៍ ណាមួយ ជាអ្នកមានចិត្តងោកជ្រប់ លង់ស៊ប់ ជាអ្នកមិនឃើញ ទោស មិនមានប្រាជ្ញាជាគ្រឿងរលាស់ខ្លួនចេញ «បច្ច- វេក្ខណញ្ញាណ » តែងបរិភោគកាមគុណទាំង ៥ នេះ សមណៈ ឬ ព្រាហ្មណ៍ ទាំងនោះ បណ្ឌិតគប្បីជ្រាបយ៉ាងនេះថា ជាអ្នកដល់នូវសេចក្តីមិនចម្រើន ដល់នូវសេចក្តីវិនាស ជាអ្នកត្រូវ មារមានចិត្តបាបនឹងធ្វើទៅតាមសេចក្តីប្រាថ្នាបាន ។

# រូបាវចរកុសលចិត្តជួនទី ៤

## ៤-សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានកុសលចិត្តំ ។

ចតុត្ថជ្ឈានកុសលចិត្ត ដែលកើតឡើងព្រមដោយអង្គ ឈាន ២ គឺ សុខៈ ឯកគ្គតា ។

### មានចេតសិកប្រកប ៣២

- អញ្ញាសមាចេតសិក ១០ ( វៀរ វិតក្កៈ វិចារៈ បីតិ )
- សោភណចេតសិក ២២ (វៀរវិរតិ ៣ ) ។

### ចែកជាខន្ធ

- វេទនាចេតសិក ជាវេទនាខន្ធ
- សញ្ញាចេតសិក ជាសញ្ញាខន្ធ
- ចេតសិក ៣០ ជាសង្ខារក្ខន្ធ
- រូបាវចរកុសលចិត្ត ជាវិញ្ញាណក្ខន្ធ ។

### ចែកជាធាតុ

- ចេតសិក ៣២ ជាធម្មធាតុ
- រូបាវចរកុសលចិត្ត ជាមនោវិញ្ញាណធាតុ ។

### ចែកជាអាយតន

- ចេតសិក ៣២ ជាធម្មាយតន
- រូបាវចរកុសលចិត្ត ជាមនាយតន ។

## ចែកជាសច្ចៈ

- ចេតសិក ៣២ ជាទុក្ខសច្ច
- រូបាវចរកុសលចិត្ត ជាទុក្ខសច្ច ។

# ធម៌អប់រំចិត្ត

ស្តីអំពី ការឧបមានៃកាមគុណ ៥ ប្រការ

( ស្រង់ចាក មជ្ឈិមនិកាយ បិដកលេខ ២១ ទំព័រ ១៦៤ )

ម្នាលភិក្ខុទាំងឡាយ ដូចជាម្រឹគនៅក្នុងព្រៃ ដែលជាប់អន្ទាក់ ហើយគប្បីដេកនូវសង្កត់គំនរអន្ទាក់ ម្រឹគនោះបណ្ឌិតគប្បីជ្រាបយ៉ាងនេះថា ជាសត្វដល់នូវសេចក្តីមិនចម្រើន ដល់នូវសេចក្តីវិនាស ជាសត្វដែលព្រាននឹងធ្វើទៅតាមសេចក្តីប្រាថ្នាបាន កាលបើព្រានដើរមកដល់ម្រឹគនោះនឹងស្ទុះចេញទៅតាមបំណងពុំបានឡើយ សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ជាអ្នកមានចិត្តងោកជ្រប់លង់ស៊ប់ ជាអ្នកមិនឃើញទោស មិនមានប្រាជ្ញា ជាគ្រឿងរលាស់ខ្លួនចេញ បរិភោគនូវកាមគុណទាំង ៥ នេះឯង សមណព្រាហ្មណ៍ទាំងនោះ បណ្ឌិតគប្បីជ្រាបយ៉ាងនេះថា ជាអ្នកដល់នូវសេចក្តី

មិនចម្រើន ដល់នូវសេចក្តីវិនាស ជាអ្នកត្រូវមារមានចិត្តបាបនឹងធ្វើទៅតាមសេចក្តីប្រាថ្នាបាន ។ ម្នាលភិក្ខុទាំងឡាយពួកសមណព្រាហ្មណ៍ណាមួយ ជាអ្នកមានចិត្តមិនងោក មិនជ្រប់ មិនលង់ស៊ប់ ជាអ្នកឃើញទោស មានប្រាជ្ញាជា គ្រឿងរលាស់ខ្លួនចេញ តែនៅបរិភោគកាមគុណទាំង ៥ នេះ សមណព្រាហ្មណ៍ទាំងនោះ បណ្ឌិតគប្បីជ្រាប់យ៉ាងនេះថា ជាអ្នកមិនដល់នូវសេចក្តីចម្រើន មិនដល់នូវសេចក្តីវិនាស ជាអ្នកមិនត្រូវមារមានចិត្តបាប ធ្វើទៅតាមសេចក្តីប្រាថ្នាបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាម្រឹគដែលនៅក្នុងព្រៃ មិនជាប់អន្ទាក់ តែដេកសង្កត់នៅលើអន្ទាក់ ម្រឹគនោះបណ្ឌិតគប្បីជ្រាបយ៉ាងនេះថា ជាសត្វមិនដល់នូវសេចក្តីមិនចម្រើន មិនដល់នូវសេចក្តីវិនាស ជាសត្វមិនត្រូវព្រានធ្វើទៅតាមសេចក្តីប្រាថ្នា បានទុកជាព្រានដើរមកដល់ម្រឹគនោះនឹងស្ទុះ ទៅតាមសេចក្តីប្រាថ្នាខ្លួនបាន សេចក្តីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចជាសមណព្រាហ្មណ៍ណាមួយ ជាអ្នកមានចិត្តមិនងោក មិនជ្រប់ មិនលង់ស៊ប់ ជាអ្នកឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ខ្លួនចេញ តែនៅបរិភោគកាមគុណ ៥ នេះនៅឡើយ សមណព្រាហ្មណ៍ទាំងនោះ បណ្ឌិតគប្បីជ្រាបយ៉ាងនេះថា ជាអ្នកមិនដល់នូវសេចក្តីមិនចម្រើន មិនដល់នូវ

សេចក្តីវិនាស ជាអ្នកមិនត្រូវមារមានចិត្តបាប ធ្វើទៅតាមសេចក្តីប្រាថ្នាបានឡើយ ។

## រូបាវចរកុសលចិត្តដួងទី ៥

*៥-ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានកុសលចិត្តំ ។*

បញ្ចមជ្ឈានកុសលចិត្ត ដែលកើតឡើងព្រមដោយអង្គ ឈាន ២ គឺឧបេក្ខា និងឯកគ្គតា ។

*មានចេតសិកប្រកប ៣០*

- អញ្ញាសមាចេតសិក១០ ( វៀរ វិតក្កៈវិចារៈបីតិ )
- សោភណចេតសិក ២០(វៀរវិរតិ៣អប្បមញ្ញា២)។

*ចែកជាខន្ធ*

- វេទនាចេតសិក ជាវេទនាខន្ធ
- សញ្ញាចេតសិក ជាសញ្ញាខន្ធ
- ចេតសិក ២៨ ជាសង្ខារក្ខន្ធ
- រូបាវចរកុសលចិត្ត ជាវិញ្ញាណក្ខន្ធ ។

*ចែកជាធាតុ*

- ចេតសិក ៣០ ជាធម្មធាតុ
- រូបាវចរកុសលចិត្ត ជាមនោវិញ្ញាណធាតុ ។

*ចែកជាអាយតន*

- ចេតសិក ៣០ ជាធម្មាយតន
- រូបាវចរកុសលចិត្ត ជាមនាយតន ។

*ចែកជាសច្ចៈ*

- ចេតសិក ៣០ ជាទុក្ខសច្ច
- រូបាវចរកុសលចិត្ត ជាទុក្ខសច្ច ។

# ធម៌អប់រំចិត្ត

## ស្តីអំពី ឱវាទដែលមានឧបមាដូចជារណារ

( ចាក មជ្ឈិមនិកាយ បិដកលេខ ២១ ទំព័រ ១៩៧ )

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើចោរទាំងឡាយ ជាអ្នកធ្វើនូវអំពើថោកទាប គប្បីអាររអវៈយវៈតូចធំទាំងឡាយ ដោយរណារដែលមានដងទាំងពីរខាង ភិក្ខុណាមួយមានចិត្តមិន អត់ធន់ប្រទូស្តរ៉ាយព្រោះជម្ងឺដែលពួកចោរអារនោះ ភិក្ខុ នោះឈ្មោះថា

មិនធ្វើតាមពាក្យប្រដៅរបស់តថាគត ដោយហេតុមិនអត់ធន់នោះ ។ ភិក្ខុនោះគិតថា សេចក្ដីព្យាយាមដែលអាត្មាអញប្រារព្ធហើយ មិនធូរថយឡើយ សតិដែលអាត្មាអញតាំងខ្ជាប់ខ្ជួនហើយ មិនភ្លាំងភ្លាត់ឡើយ កាយដែលស្ងប់ស្ងាប់ហើយមិនរសាប់រសល់ឡើយ ចិត្តដែលតម្កល់នឹងហើយ ជាចិត្តមានអារម្មណ៍តែមួយ ឥឡូវនេះ ទោះសម្ផស្ស ដៃ (ពាល់) ត្រូវក្ដីសម្ផស្សដុំដីត្រូវក្ដី សម្ផស្សគ្រឿងសាស្ត្រក្ដី ត្រង់កាយនេះក៏ត្រូវចុះអាត្មាអញនៅតែធ្វើតាមពុទ្ធសាសនានេះ ។ ម្នាលអ្នកដ៏មានអាយុទាំងឡាយ កាលបើភិក្ខុនោះ រលឹកនូវព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃ យ៉ាងនេះហើយ ឧបេក្ខា[1] ដែលអាស្រ័យនឹងកុសលក៏មិនទាន់តាំងនៅនឹងបាន ។ ភិក្ខុនោះក៏តក់ស្លុត ដល់នូវសេចក្ដីសង្វេគ ដោយហេតុថា ឱហ្ន៎ ! យើងជាមនុស្សឥតលាភ ឱហ្ន៎ ! យើងជាមនុស្សមិនមានលាភ ឱហ្ន៎ ! អត្តភាពជាមនុស្សយើងបានដោយកម្រ ឱហ្ន៎ ! អត្តភាពជាមនុស្សយើងមិនមែនបាន

---

1) *ត្រង់ពាក្យថា ឧបេក្ខាអាស្រ័យកុសលនោះ បានដល់វិបស្សនូបេក្ខា និងឆឡង្គុបេក្ខាទាំងនេះ ។ ឯឆឡង្គុបេក្ខា ១ នេះ ជារបស់ព្រះខីណាស្រពលោកមិនត្រេកអរ មិនទោមនស្សក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ឡើយ ។ ភិក្ខុត្រូវតាំងវិបស្សនារបស់ខ្លួនទុកក្នុងឆឡង្គុបេក្ខា របស់ព្រះខីណាស្រពនោះ ដោយកម្លាំងសេចក្ដីព្យាយាម និងសម្រេចដោយភាវនា ។ អដ្ឋកថា ។*

ដោយងាយទេ ត្រង់ដែលអាត្មាអញ រលឹកនូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ យ៉ាងនេះហើយ ឧបេក្ខាដែលអាស្រ័យនឹងកុសល ក៏មិនទាន់ តាំងនៅនឹងបាន។

## រូបាវចរវិបាកចិត្ត ៥ ដួង

## រូបាវចរវិបាកចិត្តដួងទី ១

*១-វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈាន-វិបាកចិត្តំ ។*

បឋមជ្ឈានវិបាកចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ៥ គឺវិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា ។

*មានចេតសិកប្រកប ៣៥*

- អញ្ញាសមាចេតសិក ១៣
- សោភណចេតសិក ២២ (វៀរវិរតិ ៣) ។

*ចែកជាខន្ធ*

- វេទនាចេតសិក ជាវេទនាខន្ធ
- សញ្ញាចេតសិក ជាសញ្ញាខន្ធ
- ចេតសិក ៣៣ ជាសង្ខារក្ខន្ធ
- រូបាវចរវិបាកចិត្ត ជាវិញ្ញាណក្ខន្ធ ។

*ចែកជាធាតុ*

- ចេតសិក ៣៥ ជាធម្មធាតុ
-រូបាវចរកុសលចិត្ត ជាមនោវិញ្ញាណធាតុ

*ចែកជាអាយតន*

- ចេតសិក ៣៥ ជាធម្មាយតន
- រូបាវចរវិបាកចិត្ត ជាមនាយតន ។

*ចែកជាសច្ច*

- ចេតសិក ៣៥ ជាទុក្ខសច្ច
- រូបាវចរវិបាកចិត្ត ជាទុក្ខសច្ច ។

## **ធម៌អប់រំចិត្ត**

ស្តីអំពីឧទាននៃព្រះសម្ពុទ្ធ

(ចាកខុទ្ទកនិកាយ ឧទាន បិដកលេខ ៥២ ទំព័រ ២៥៩)

*ទិស្វា អាទីនវំ លោកេ ញត្វា ធម្មំ និរូបធឹ*
*អរិយោ ន រមតិ បាបេ បាបេ ន រមតិ សុចីតិ ។*

ព្រះអរិយៈឃើញទោស ក្នុងសង្ខារលោកដឹងនូវព្រះ និព្វាន ធម៌ដែលគ្មានឧបធិហើយ រមែងមិនត្រេកអរក្នុងបាប (ដូច) បុគ្គលស្អាត់មិនត្រេកអរក្នុងវត្ថុអាក្រក់ ។

# រូបាវចរវិបាកចិត្តដួងទី ២

២. *វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានវិបាក-ចិត្តំ* ។

ទុតិយជ្ឈានវិបាកចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ៤ គឺ វិចារៈ បីតិ សុខៈ ឯកគ្គតា ។

*មានចេតសិកប្រកប ៣៤*

-អញ្ញសមានាចេតសិក ១២ (វៀរវិតក្កៈ)

-សោភណចេតសិក ២២ (វៀរវិរតិ ៣) ។

*ចែកជាខន្ធ*

- វេទនាចេតសិក ជាវេតនាខន្ធ
- សញ្ញាចេតសិក ជាសញ្ញាខន្ធ
- ចេតសិក ៣២ ជាសង្ខារក្ខន្ធ
- រូបាវចរវិបាកចិត្ត ជាវិញ្ញាណក្ខន្ធ ។

*ចែកជាធាតុ*

- ចេតសិក ៣៤ ជាធម្មធាតុ
- រូបាវចរវិបាកចិត្ត ជាមនោវិញ្ញាណធាតុ ។

*ចែកជាអាយតន*

| | |
|---|---|
| - ចេតសិក ៣៤ | ជាធម្មាយតន |
| - រូបាវចរវិបាកចិត្ត | ជានាយតន ។ |

*ចែកជាសច្ច*

| | |
|---|---|
| -ចេតសិក ៣៤ | ជាទុក្ខសច្ច |
| -រូបាវចរវិបាកចិត្ត | ជាទុក្ខសច្ច ។ |

# ធម៌អប់រំចិត្ត

ស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ

(ចាកខុទ្ទកនិកាយ ឧទាន បិដកលេខ ៥២ ទំព័រ ២៥៩)

*យា កាចិ កង្ខា ឥធ វា ហុរំ វា*
*សកវេទិយា វា បរវេទិយា វា*
*យេ ឈាយិនោ តា បជហន្តិ សព្វា*
*អាតាបិនោ ព្រហ្មចរិយំ ចរន្តាតិ ។*

សេចក្ដីសង្ស័យទាំងឡាយណាមួយ ក្នុងលោកនេះក្ដី ក្នុងលោកខាងមុងក្ដី ដែលបុគ្គលគប្បីដឹងក្នុងអត្តភាព របស់ ខ្លួន ឬ គប្បីដឹងក្នុងអត្តភាពរបស់បុគ្គលដទៃ បុគ្គលអ្នកមាន ឈានមានព្យាយាម កាលប្រព្រឹត្តព្រហ្មចរិយធម៌ រមែងលះបង់ នូវ សេចក្ដីសង្ស័យទាំងអស់នោះបាន ។

## រូបាវចរវិបាកចិត្តដួងទី ៣

*៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានវិបាកចិត្ត ។*

តតិយជ្ឈានវិបាកចិត្ត ដែលកើតឡើងព្រមដោយអង្គ ឈាន ៣ គឺ បីតិ សុខៈ ឯកគ្គតា ។

*មានចេតសិកប្រកប ៣៣*

-អញ្ញសមានាចេតសិក ១១ (វៀរវិតក្កៈ វិចារៈ)

-សោភណចេតសិក ២២ (វៀរវិរតិ ៣) ។

*ចែកជាខន្ធ*

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣១ ជាសង្ខារក្ខន្ធ
-រូបាវចរវិបាកចិត្ត ជាវិញ្ញាណក្ខន្ធ ។

*ចែកជាធាតុ*

-ចេតសិក ៣៣ ជាធម្មធាតុ
-រូបាវចរវិបាកចិត្ត ជាមនោវិញ្ញាណធាតុ ។

*ចែកជាអាយតន*

-ចេតសិក ៣៣ ជាធម្មាយតន
-រូបាវចរវិបាកចិត្ត ជាមនាយតន ។

*ចែកជាសច្ច*

-ចេតសិក ៣៣ ជាទុក្ខសច្ច
-រូបាវចរវិបាកចិត្ត ជាទុក្ខសច្ច ។

## ធម៌អប់រំចិត្ត

ស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ

(ចាកខុទ្ទនិកាយ ឧទាន បិដក ៥២ ទំព័រ ១២៦)

*ន ឧទកេន សុចិ ហោតិ ពហ្វេត្ថ ន្ហាយតី ជនោ*
*យម្ហិ សច្ចញ្ច ធម្មោ ច សោ សុចី សោ ច*
*ព្រាហ្មណោតិ ។*

បុគ្គលមិនមែនស្អាតព្រោះទឹកទេ (ព្រោះ) អ្នកផងច្រើនគ្នាវមែងងូតទឹកនុ៎ះដែរ សច្ចៈ១[2] ធម្មៈ១[3] (មាននៅ) ក្នុងបុគ្គលណា បុគ្គលនោះទើបឈ្មោះថា ជាអ្នកស្អាតផង ឈ្មោះថាជាព្រាហ្មណ៍ផង ។

## រូបាវចរវិបាកចិត្តដួងទី ៤

*៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានវិបាកចិត្តំ ។*

ចតុត្ថជ្ឈានវិបាកចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ សុខៈ ឯកគ្គតា ។

*មានចេតសិកប្រកប ៣២*

-អញ្ញសមានាចេតសិក ១០ (វៀរ វិតក្កៈ វិចារៈ បីតិ)

-សោភណចេតសិក ២២ (វៀរ វិរតិ ៣) ។

*ចែកជាខន្ធ*

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

---

(2) *បានដល់វចីសច្ចៈ និងវិរតិសច្ចៈ ឬជាញាណសច្ចៈ និងបរមត្ថសច្ចៈ*

(3) *បានដល់អរិយសច្ចធម៌ និងអរិយផលធម៌ ។ អដ្ឋកថា ។*

| | |
|---|---|
| -ចេតសិក ៣០ | ជាសង្ខារក្ខន្ធ |
| -រូបាវចរវិបាកចិត្ត | ជាវិញ្ញាណក្ខន្ធ ។ |

## *ចែកជាធាតុ*

| | |
|---|---|
| -ចេតសិក ៣២ | ជាធម្មធាតុ |
| -រូបាវចរវិបាកចិត្ត | ជាមនោវិញ្ញាណធាតុ ។ |

## *ចែកជាអាយតន*

| | |
|---|---|
| -ចេតសិក ៣២ | ជាធម្មាយតន |
| -រូបាវចរវិបាកចិត្ត | ជាមនាយតន |

## *ចែកជាសច្ច*

| | |
|---|---|
| -ចេតសិក ៣២ | ជាទុក្ខសច្ច |
| -រូបាវចរវិបាកចិត្ត | ជាទុក្ខសច្ច ។ |

# ធម៌អប់រំចិត្ត

## ស្ដីអំពី ឧទាននៃព្រះសម្ពុទ្ធ

(ចាកខុទ្ទកនិកាយ ឧទាន បិដកលេខ ៥២ ទំព័រ ១៣៤)

*សុខោ វិវេកោ តុដ្ឋស្ស   សុតធម្មស្ស បស្សតោ*
*អព្យាបជ្ឈំ សុខំ លោកេ   បាណភូតេសុ សញ្ញមោ*
*សុខា វិរាគតា លោកេ   កាមានំ សមតិក្កមោ*
*អស្មិមានស្ស វិនយោ   ឯតំ វេ បរមំ សុខន្តិ ។*

វិវេក[4] របស់បុគ្គលអ្នកត្រេកអរ (ដោយមគ្គញ្ញាណ) មានធម៌ស្ដាប់ហើយ បានឃើញច្បាស់ (ដោយញាណចក្ខុ) នាំមក នូវសុខ ការមិនបៀតបៀនគ្នា និង ការសង្រួមក្នុងសត្វទាំងឡាយ ជាសុខក្នុងលោក កិរិយាកំចាត់បង់នូវអស្មិមានៈ ដំណើរនុ៎ះ ឈ្មោះថា នាំមកនូវសេចក្ដីសុខដ៏ក្រៃលែង ។

---

[4] *វិវេកក្នុងទីនេះ សំដៅដល់ឧបធិវិវេក ។*

# រូបាវចរវិបាកចិត្តដួងទី ៥

## ៥. ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានវិបាកចិត្តំ ។

បញ្ចមជ្ឈានវិបាកចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា និង ឯកគ្គតា ។

### មានចេតសិកប្រកប ៣០

-អញ្ញសមានាចេតសិក ១០ (វៀរវិតក្កៈ វិចារៈ បីតិ)

-សោភណចេតសិក ២០ (វៀរវិរតិ ៣ អប្បមញ្ញា ២)។

### ចែកជាខន្ធ

| | |
|---|---|
| -វេទនាចេតសិក | ជាវេទនាខន្ធ |
| -សញ្ញាចេតសិក | ជាសញ្ញាខន្ធ |
| -ចេតសិក ២៨ | ជាសង្ខារក្ខន្ធ |
| -រូបាវចរវិបាកចិត្ត | ជាវិញ្ញាណក្ខន្ធ ។ |

### ចែកជាធាតុ

| | |
|---|---|
| -ចេតសិក ៣០ | ជាធម្មធាតុ |
| -រូបាវចរវិបាកចិត្ត | ជាមនោវិញ្ញាណធាតុ ។ |

### ចែជាអាយតន

| | |
|---|---|
| -ចេតសិក ៣០ | ជាធម្មាយតន |
| -រូបាវចរវិបាកចិត្ត | ជាមនាយតន ។ |

*ចែកជាសច្ច*

-ចេតសិក ៣០ ជាទុក្ខសច្ច

-រូបាវចរវិបាកចិត្ត ជាទុក្ខសច្ច ។

## ធម៌អប់រំចិត្ត

ស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ

(ចាកខុទ្ទកនិកាយ ឧទាន បិដកលេខ ៥២ ទំព័រ ២២៣)

*យំ ជីវិតំ ន តបតិ មរណន្តេ ន សោចតិ*

*សចេ ទិដ្ឋបទោ ធីរោ សោកមជ្ឈេ ន សោចតិ ។*

*ឧច្ឆិន្នភវតណ្ហស្ស សន្តចិត្តស្ស ភិក្ខុនោ*

*វិក្ខីណោ ជាតិសំសារោ នត្ថិ តស្ស បុនព្ភវោតិ ។*

ជីវិតរបស់បុគ្គលណា មិនក្តៅក្រហាយបុគ្គលនោះរមែងមិនសោកក្នុងកាលជិតស្លាប់ ប្រសិនបើអ្នកប្រាជ្ញនោះ ឯងបានឃើញបទគឺព្រះនិព្វាន រមែងមិនសោកក្នុងកណ្តាលពួកអ្នកសោកឡើយ ។ ភិក្ខុបានគាស់រំលើងតណ្ហាក្នុងភពមានចិត្តស្ងប់ មានជាតិសង្សារអស់ហើយភពថ្មីទៀត មិនមានដល់ភិក្ខុឡើយ ។

# **រូបាវចរកិរិយាចិត្ត ៥ ដួង**

## *រូបាវចរកិរិយាចិត្តដួងទី ១*

*១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈាន-កិរិយាចិត្តំ ។*

បឋមជ្ឈានកិរិយាចិត្ត ដែលកើងឡើងព្រមដោយអង្គឈាន ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា ។

*មានចេតសិកប្រកប ៣៥*

-អញ្ញសមានាចេតសិក ១៣

-សោភណចេតសិក ២២ (វៀរ វរតិ ៣) ។

*ចែកជាខន្ធ*

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣៣ ជាសង្ខារក្ខន្ធ

-រូបាវចរកិរិយាចិត្ត ជាវិញ្ញាណក្ខន្ធ ។

*ចែកជាធាតុ*

-ចេតសិក ៣៥ ជាធម្មធាតុ

-រូបាវចរកិរិយា ជាមនោវិញ្ញាណធាតុ ។

*ចែកជាអាយតន*

-ចេតសិក ៣៥ ជាធម្មាយតន

-រូបាវចរកិរិយាចិត្ត ជាមនាយតន ។

*ចែកជាសច្ច*

-ចេតសិក ៣៥ ជាទុក្ខសច្ច

-រូបាវចរកិរិយាចិត្ត ជាទុក្ខសច្ច ។

# ធម៌អប់រំចិត្ត

ស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ

(ចាកខុទ្ទកនិកាយ ឧទាន បិដកលេខ ៥២ ទំព័រ ១៨៨)

*អសិប្បជីវី លហុ អត្ថកាមោ*

*យតិន្ទ្រិយោ សព្វធិ វិប្បមុត្តោ*

*អនោកសារី អមមោ និរាសោ*

*ហន្វា មារំ ឯកចរោ ស ភិក្ខូតិ ។*

បុគ្គលណា ជាអ្នកមិនចិញ្ចឹមជីវិតដោយសិល្បៈ ជាអ្នកប្រព្រឹត្តស្រាល ប្រាថ្នាប្រយោជន៍ ដល់ជនដទៃ សង្រួមឥន្ទ្រិយ៍ មានចិត្តផុតស្រឡះចាកអាសវៈទាំងពួង មិនមានទីនៅនៃ តណ្ហា

មិនមានសេចក្តីប្រកាន់ថារបស់អញ មិនមានសេចក្តីប្រាថ្នា បានសម្លាប់មារហើយចរទៅម្នាក់ឯង បុគ្គលនោះ ឈ្មោះថា ភិក្ខុ ។

## រូបាវចរកិរិយាចិត្តជួងទី ២

*២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈាន-កិរិយាចិត្តំ ។*

ទុតិយជ្ឈានកិរិយាចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ៤ គឺ វិចារៈ បីតិ សុខៈ ឯកគ្គតា ។

*មានចេតសិកប្រកប ៣៤*

-អញ្ញសមាចេតសិក ១២ (វៀរវិតក្កៈ)

-សោភណចេតសិក ២២ (វៀរវិរតិ ៣) ។

*ចែកជាខន្ធ*

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣២ ជាសង្ខារក្ខន្ធ

-រូបាវចរកិរិយាចិត្ត ជាវិញ្ញាណក្ខន្ធ ។

*ចែកជាធាតុ*

-ចេតសិក ៣៤ ជាធម្មធាតុ

-រូបាវចរកិរិយាចិត្ត ជាមនោវិញ្ញាណធាតុ ។

*ចែកជាអាយតន*

-ចេតសិក ៣៤ ជាធម្មាយតន

-រូបាវចរកិរិយាចិត្ត ជាមនាយតន ។

*ចែកជាសច្ចៈ*

-ចេតសិក ៣៤ ជាទុក្ខសច្ច

-រូបាវចរកិរិយាចិត្ត ជាទុក្ខសច្ច ។

# ធម៌អប់រំចិត្ត

ស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ

(ចាក ខុទ្ទកនិកាយ ឧទាន បិដកលេខ ៥២ ទំព័រ ១៨៩)

សត្វលោកនេះមានសេចក្តីក្តៅអន្ទះសា ត្រូវផស្សៈគ្របសង្កត់ហើយ រមែងពោលនូវខន្ធបញ្ចកៈ ដែលមានរោគថាជាខ្លួន ព្រោះសំគាល់ថាឃើញដោយអាការៈណាខន្ធបញ្ចកៈនោះ រមែងប្រែក្លាយទៅចាកអាការៈនោះ សត្វលោកជាប់ជំពាក់ក្នុងភព ត្រូវភពគ្របសង្កត់ មានការប្រែក្លាយជាធម្មតាតែង ត្រេកត្រអាល

នឹងភព ។ សត្វត្រេកអរនឹងរបស់ណារបស់នោះជាភ័យខ្លាច ចំពោះរបស់ណារបស់នោះជាទុក្ខ មានតែបុគ្គលអ្នកប្រព្រឹត្តមគ្គព្រហ្មចរិយនេះ ទើបលះបង់ភពបាន ។

## រូបាវចរកិរិយាចិត្តជួនទី ៣

*៣.វិចារបីតិសុខេកគ្គតាសហិតំ តតិយជ្ឈានកិរិយាចិត្តំ ។*

តតិយជ្ឈានកិរិយាចិត្ត ដែលកើតឡើងព្រមដោយអង្គ ៣ គឺ បីតិ សុខៈ ឯកគ្គតា ។

### *មានចេតសិកប្រកប ៣៣*

-អញ្ញសមានាចេតសិក ១១ (វៀរវិតក្កៈ វិចារៈ)

-សោភណចេតសិក ២២ (វៀរវិរតិ ៣) ។

### *ចែកជាខន្ធ*

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៣១ ជាសង្ខារក្ខន្ធ

-រូបាវចរកិរិយាចិត្ត ជាវិញ្ញាណក្ខន្ធ ។

### *ចែកជាធាតុ*

| | |
|---|---|
| -ចេតសិក ៣៣ | ជាធម្មធាតុ |
| -រូបាវចរកិរិយាចិត្ត | ជាមនោវិញ្ញាណធាតុ ។ |

### *ចែកជាអាយតន*

| | |
|---|---|
| -ចេតសិក ៣៣ | ជាធម្មាយតន |
| -រូបាវចរកិរិយាចិត្ត | ជាមានាយតន ។ |

### *ចែកជាសច្ច*

| | |
|---|---|
| -ចេតសិក ៣៣ | ជាទុក្ខសច្ច |
| -រូបាវចរកិរិយាចិត្ត | ជាទុក្ខសច្ច ។ |

## **ធម៌អប់រំចិត្ត**

ស្ដីអំពី ឧទាននៃព្រះសម្ពុទ្ធ

(ចាកខុទ្ទកនិកាយ ឧទាន បិដកលេខ ៥២ ទំព័រ ១៥៩)

*សព្វកម្មជហស្ស ភិក្ខុនោ*
*ធុនមានស្ស បុរេក្ខតំ រជំ*
*អមមស្ស ឋិតស្ស តាទិនោ*
*អត្ថោ នត្ថិ ជនំ លបេតវេតិ ។*

ភិក្ខុអ្នកលះបង់កម្មទាំងពួង កំចាត់បង់នូវធូលីគឺកិលេស ដែលខ្លួនធ្លាប់ធ្វើក្នុងកាលមុន មិនមានសេចក្តីប្រកាន់ ថាអញ ឋិតនូវនឹងធឹងសេចក្តីត្រូវការដើម្បីហៅរក[5] អ្នកផងឱ្យជួយមិនមានឡើយ ។

## រូបាវចរកិរិយាចិត្តជួនទី ៤

*៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានកិរិយាចិត្តំ ។*

ចតុត្ថជ្ឈានកិរិយាចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ សុខៈ ឯកគ្គតា ។

*មានចេតសិកប្រកប ៣២*

-អញ្ញសមានាចេតសិក ១០ (វៀរ វិតក្កៈ វិចារៈ បីតិ)
-សោភណចេតសិក ២២ (វៀរវិរតិ ៣)។

*ចែកជាខន្ធ*

-វេទនាចេតសិក ជាវេទនាខន្ធ
-សញ្ញាចេតសិក ជាសញ្ញាខន្ធ
-ចេតសិក ៣០ ជាសង្ខារក្ខន្ធ
-រូបាវចរកិរិយាចិត្ត ជាវិញ្ញាណក្ខន្ធ ។

---

[5] *ប្រយោជន៍ដើម្បីហៅរកអ្នកផងថា អ្នកទាំងឡាយចូរធ្វើថ្នាំជាដើម ដល់អាត្មាអញ ដូច្នេះមិនមានឡើយ ព្រោះលោកឥតមានសេចក្តី អាឡោះអាល័យក្នុងសរីរៈ។*

## *ចែកជាធាតុ*

-ចេតសិក ៣២ ជាធម្មធាតុ
-រូបាវចរកិរិយាចិត្ត ជានោមវិញ្ញាណធាតុ ។

## *ចែកជាអាយតន*

-ចេតសិក ៣២ ជាធម្មាយតន
-រូបាវចរកិរិយាចិត្ត ជាមនាយតន ។

## *ចែកជាសច្ច*

-ចេតសិក ៣២ ជាទុក្ខសច្ច
-រូបាវចរកិរិយាចិត្ត ជាទុក្ខសច្ច ។

# **ធម៌អប់រំចិត្ត**

### ស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ

(ចាកខុទ្ទកនិកាយ ឧទាន បិដកលេខ ៥២ ទំព័រ ១៦៧)

*យស្ស តិណ្ណោ កាមបង្កោ*
*មទ្ទិតោ កាមកណ្ដកោ*
*មោហក្ខយំ អនុប្បត្តោ*
*សុខទុក្ខេសុ ន វេធតី ស ភិក្ខូតិ ។*

ភិក្ខុណា បានឆ្លងភក់គឺកាម បានញាំញីបន្លាគឺ កាម ភិក្ខុនោះ បានដល់នូវការអស់ទៅនៃមោហៈ រមែងមិនញាប់ញ័រ ព្រោះសុខ និង ទុក្ខឡើយ ។

## រូបាវចរកិរិយាចិត្តជួរទី ៥

*៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានកិរិយាចិត្តំ ។*

បញ្ចមជ្ឈានកិរិយាចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា ឯកគ្គតា ។

*មានចេតសិកប្រកប ៣០*

-អញ្ញសមានាចេតសិក ១០ (វៀរ វិតក្កៈ វិចារៈ បីតិ)

-សោភណចេតសិក ២០ (វៀរវិរតិ៣ អប្បមញ្ញា២) ។

*ចែកជាខន្ធ*

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ២៨ ជាសង្ខារក្ខន្ធ

-រូបាវចរកិរិយាចិត្ត ជាវិញ្ញាណក្ខន្ធ ។

## ចែកជាធាតុ

-ចេតសិក ៣០ ជាធម្មធាតុ

-រូបាវចរកិរិយាចិត្ត ជាមនោវិញ្ញាណធាតុ ។

## ចែកជាអាយតន

-ចេតសិក ៣០ ជាធម្មាយតន

-រូបាវចរកិរិយាចិត្ត ជាមនាយតន ។

## ចែកជាសច្ចៈ

-ចេតសិក ៣០ ជាទុក្ខសច្ច

-រូបាវចរកិរិយាចិត្ត ជាទុក្ខសច្ច ។

# ធម៌អប់រំចិត្ត

ស្ដីអំពី ឧទាននៃព្រះសម្ពុទ្ធ

(ចាកខុទ្ទកនិកាយ ឧទាន បិដកលេខ ៥២ ទំព័រ ១៧៤)

*យស្ស ជិតោ កាមកណ្ដកោ*
*អក្កោសោ ច វធោ ច ពន្ធនញ្ច*
*បព្វតោ វិយ សោ ឋិតោ អនេជោ*
*សុខទុក្ខេសុ ន វេធតី ស ភិក្ខុតិ ។*

បន្ទាគឺកាម កិរិយាជេរ ការសម្លាប់ និងការចងដែលបុគ្គលណាឈ្មុះហើយ បុគ្គលនោះឈ្មោះថា មិនញាប់ញ័រឋិតនៅដូចភ្នំ បុគ្គលនោះឈ្មោះថាភិក្ខុ រមែងមិនញាប់ញ័រព្រោះសុខ និងទុក្ខឡើយ ។

## អរូបាវចរចិត្ត ១២ ដួង

*អរូបាវចរកុសលចិត្ត ៤ ដួង*

**អរូបាវចរកុសលចិត្តដួងទី ១**

*១.ឧបេក្ខេកគ្គតាសហិតំ អាកាសានញ្ចាយតនកុសលចិត្តំ ។*

អាកាសានញ្ចាយតនកុសលចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា ឯកគ្គតា ។

*មានចេតសិកប្រកប ៣០*

-អញ្ញសមានាចេតសិក ១០ (វៀរ វិតក្កៈ វិចារៈ បីតិ)

-សោភណចេតសិក ២០ (វៀរវិរតិ ៣ អប្បសញ្ញា ២)។

### *ចែកជាខន្ធ*

-វេទនាចេតសិក ជាវេទនាខន្ធ
-សញ្ញាចេតសិក ជាសញ្ញាខន្ធ
-ចេតសិក ២៨ ជាសង្ខារក្ខន្ធ
-អរូបាវចរកុសលចិត្ត ជាវិញ្ញាណក្ខន្ធ ។

### *ចែកជាធាតុ*

-ចេតសិក ៣០ ជាធម្មធាតុ
-អរូបាវចរកុសលចិត្ត ជាមនោវិញ្ញាណធាតុ ។

### *ចែកជាអាយតន*

-ចេតសិក ៣០ ជាធម្មាយតន
-អរូបាវចរកុសលចិត្ត ជាមនាយតន ។

### *ចែកជាសច្ច*

-ចេតសិក ៣០ ជាទុក្ខសច្ច
-អរូបាវចរកុសលចិត្ត ជាទុក្ខសច្ច ។

## ធម៌អប់ចិត្ត

ស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ

(ចាកខុទ្ទកនិកាយ ឧទាន បិដកលេខ ៥២ ទំព័រ ២១៥)

*អធិចេតសោ អប្បមជ្ជតោ*

*មុនិនោមោនបថេសុ សិក្ខតោ*

*សោកា ន ភវន្តិ តាទិនោ*

*ឧបសន្តស្ស សទា សតីមតោតិ ។*

សេចក្តីសោកទាំងឡាយ រមែងមិនកើតមានដល់បុគ្គលអ្នកមានអធិចិត្ត មិនប្រមាទ ជាអ្នកដឹង ជាអ្នកសិក្សាក្នុងផ្លូវនៃការដឹងទាំងឡាយ គឺជាអរហត្តផលញ្ញាណមានចិត្តមិនញាប់ញ័រ ជាអ្នកនឹងធឹង ជាអ្នកស្ងប់ មានស្មារតីគ្រប់កាល ។

**អរូបាវចរកុសលចិត្តដួងទី ២**

*២.ឧបេក្ខេកគ្គតាសហិតំ វិញ្ញាណញ្ចាយតនកុសលចិត្តំ ។*

វិញ្ញាណញ្ចាយតនកុសលចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា ឯកគ្គតា ។

*មានចេតសិកប្រកប ៣០*

-អញ្ញសមានាចេតសិក ១០ (វៀរវិតក្កៈ វិចារៈ បីតិ)

-សោភណចេតសិក ២០ (វៀរវិរតិ ៣ អប្បមញ្ញា ២)

*ចែកជាខន្ធ*

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ២៨ ជាសង្ខារក្ខន្ធ

-អរូបាវចកុសលចិត្ត ជាវិញ្ញាណក្ខន្ធ ។

*ចែកជាធាតុ*

-ចេតសិក ៣០ ជាធម្មធាតុ

-អរូបាវចរកុសលចិត្ត ជាមនោវិញ្ញាណធាតុ ។

*ចែកជាអាយតន*

-ចេតសិក ៣០ ជាធម្មាយតន

-អរូបាវចរកុសលចិត្ត ជាមនាយតន ។

*ចែកជាសច្ច*

-ចេតសិក ៣០ ជាទុក្ខសច្ច

-អរូបាវចរកុសលចិត្ត ជាទុក្ខសច្ច ។

## ធម៌អប់រំចិត្ត

ស្ដីអំពីឧទាននៃព្រះសម្ពុទ្ធ

(ចាកខុទ្ទកនិកាយ ឧទាន បិដកលេខ ៥២ ទំព័រ ៣២២)

*អត្ថិ ភិក្ខវេ អជាតំ អភូតំ អកតំ អសង្ខតំ នោ ចេ តំ ភិក្ខវេ អភវិស្ស អជាតំ អភូតំ អកតំ អសង្ខតំ នយិធ ជាតស្ស ភូតស្ស កតស្ស សង្ខតស្ស និស្សរណំ បញ្ញាយេថ ។ យស្មា ច ខោ ភិក្ខវេ អត្ថិ អជាតំ អភូតំ*

*អកតំ អសង្ខតំ តស្មា ជាតស្ស ភូតស្ស កតស្ស សង្ខតស្ស និស្សរណំ បញ្ញាយតីតិ ។*

ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វានឈ្មោះថា អជាតៈ[6] ឈ្មោះថា អភូតៈ[7] ឈ្មោះថា អកតៈ[8] ឈ្មោះថា អសង្ខតៈ[9] មានប្រាកដ ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើព្រះនិព្វាន នោះឈ្មោះថា អជាតៈ ឈ្មោះថា អភូតៈ ឈ្មោះថា អកតៈឈ្មោះថា អសង្ខតៈ មិនមានទេ ការរលាស់ខ្លួនចេញនូវ កិលេសដែលនាំឱ្យកើតមហាភូតរូប ដែលប្រាកដនូវហេតុ ដែលធ្វើនូវបច្ច័យ ដែលតាក់តែងនូវបច្ច័យ ក្នុងលោកនេះក៏មិនប្រាកដ(ដែរ) ។ ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វានឈ្មោះថា អជាតៈ ឈ្មោះថា អភូតៈ ឈ្មោះថា អកតៈ ឈ្មោះថា អសង្ខតៈ រមែងមានប្រាកដ ព្រោះហេតុណា ហេតុនោះ

---

*[6] ព្រះនិព្វាន ដែលឈ្មោះថា **អជាតៈ** នោះព្រោះមិនមានសេចក្តីព្រមព្រៀង ដោយហេតុនាំឲ្យកើតទៀត។ [6] ដែលឈ្មោះថា **អភូតៈ** នោះបានដល់ការមិន ប្រាកដនៃមហាភូតរូប ។ [7] ដែលឈ្មោះថា **អកតៈ** នោះគឺមិនមានហេតុណាមួយ គួរធ្វើតទៅទៀតទេ ។ [8] ដែលឈ្មោះថា **អសង្ខតៈ** នោះគឺប្រាសចាកបច្ច័យទាំង ឡាយ មានអវិជ្ជា ជាដើម ។ ចាកអដ្ឋកថា ។*

ការរលាស់ចេញនូវកិលេស ដែលនាំឱ្យកើតមហាភូតរូប ក៏ប្រាកដនូវហេតុ ដែលគួរធ្វើនូវបច្ច័យជាទីតាក់តែង ក៏រមែងប្រាកដ ។

## អរូបាវចរកុសលចិត្តដួងទី ៣

*៣-ឧបេក្ខេកគ្គតាសហិតំ អាកិញ្ចញ្ញាយតនកុសលចិត្តំ ។*

អាកិញ្ចញ្ញាយតនកុសលចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា និង ឯកគ្គតា ។

*មានចេតសិកប្រកប ៣០*

-អញ្ញសមានាចេតសិក ១០ (វៀរ វិតក្កៈ វិចារៈ បីតិ)

-សោភណចេតសិក ២០ (វៀរ វិរតិ ៣ អប្បមញ្ញា ២)។

*ចែកជាខន្ធ*

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ២៨ ជាសង្ខារក្ខន្ធ

-អរូបាវចរកុសលចិត្ត ជាវិញ្ញាណក្ខន្ធ ។

*ចែកជាធាតុ*

-ចេតសិក ៣០ ជាធម្មធាតុ

-អរូបាវចរកុសលចិត្ត ជាមនោវិញ្ញាណធាតុ ។

*ចែកជាអាយតន*

-ចេតសិក ៣០ ជាធម្មាយតន

-អរូបាវចរកុសលចិត្ត ជាមនាយន ។

*ចែកជាសច្ច*

-ចេតសិក ៣០ ជាទុក្ខសច្ច

-អរូបាវចរកុសលចិត្ត ជាមនាយតន ។

# ធម៌អប់រំចិត្ត

ស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ

(ចាកខុទ្ទកនិកាយ ឧទាន បិដកលេខ ៥២ ទំព័រ ៣៣៤)

*ទទតោ បុញ្ញំ បវឌ្ឍតិ សញ្ញមតោ វេរំ ន ចីយតិ កុសលោ ច ជហាតិ បាបកំ រាគទោសមោហក្ខយា បរិនិព្វុតោតិ ។*

បុណ្យរមែងចម្រើនដល់បុគ្គលអ្នកឱ្យ បុគ្គលអ្នកសង្រួមរមែងមិនសន្សំទុក្ខនូវពៀរទេ អ្នកឈ្លាសរមែងលះបង់នូកម្មដ៏លាមក បុគ្គលបរិញ្វានព្រោះអស់ទៅ នៃរាគៈ ទោសៈ មោហៈ ។

## អរូបាវចរកុសលចិត្តដួងទី ៤

*៤.ឧបេក្ខេកគ្គតាសហិតំនេវសញ្ញានាសញ្ញាយតនកុសលចិត្តំ ។*

នូវសញ្ញានាសញ្ញាយតនកុសលចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២គឺ ឧបេក្ខា និង ឯកគ្គតា ។

*មានចេតសិកប្រកប ៣០*

-អញ្ញសមនាចេតសិក ១០ (វៀរ វិតក្កៈ វិចារៈ បីតិ)

-សោភណចេតសិក ២០(វៀរវិរតិ ៣អប្បមញ្ញា២) ។

*ចែកជាខន្ធ*

| | |
|---|---|
| -វេទនាចេតសិក | ជាវេទនាខន្ធ |
| -សញ្ញាចេតសិក | ជាសញ្ញាខន្ធ |
| -ចេតសិក ២៨ | ជាសង្ខារក្ខន្ធ |
| -អរូបាវចរកុសលចិត្ត | ជាវិញ្ញាណក្ខន្ធ ។ |

*ចែកជាធាតុ*

| | |
|---|---|
| -ចេតសិក ៣០ | ជាធម្មធាតុ |
| -អរូបាវចរកុសលចិត្ត | ជាមនោវិញ្ញាណធាតុ ។ |

*ចែកជាអាយតន*

| | |
|---|---|
| -ចេតសិក ៣០ | ជាធម្មាយតន |
| -អរូបាវចរកុសលចិត្ត | ជាមនាយតន ។ |

## ចែកជាសច្ច

-ចេតសិក ៣០ ជាទុក្ខសច្ច

-អរូបាវចរកុសលចិត្ត ជាទុក្ខសច្ច ។

# ធម៌អប់ចិត្ត

## ស្តីអំពីឧទាននៃព្រះសម្ពុទ្ធ

(ចាកខុទ្ទកនិកាយ ឧទាន បិដកលេខ ៥២ ទំព័រ ៣៤៣)

មនុស្សជាបណ្ឌិតជាតិ សម្រេចការនៅក្នុងប្រទេសណា រមែងញុំាងពួកបុគ្គលអ្នកមានសីល សង្រួមប្រព្រឹត្តធម៌ដ៏ប្រសើរ ឱ្យបរិភោគក្នុងប្រទេសនោះ ហើយបានឧទ្ទិសផលទក្ខិណាទាន ចំពោះពួកទេវតា ដែលនៅក្នុងប្រទេសនោះ ទេវតាទាំងនោះ ដែលបណ្ឌិតនោះបូជាហើយ រមែងបូជាគេវិញ ដែលរាប់អាន ហើយរមែងរាប់អានគេវិញ តែអនុគ្រោះបណ្ឌិតនោះ ព្រោះទណ្ឌិណានុប្បទាននោះ ដូចមាតាអនុគ្រោះបុត្រ ដែលកើតអំពីទ្រូងបុរស ដែលទេវតាអនុគ្រោះហើយ តែឃើញនូវសេចក្តីចម្រើនគ្រប់កាល ។

## **អរូបាវចរវិបាកចិត្ត ៤ ដួង**

### *អរូបាវចរវិបាកចិត្តដួងទី ១*

*១.ឧបេក្ខេកគ្គតាសហិតំ អាកាសានញ្ចាយតនវិបាក-ចិត្តំ ។*

អាកាសានញ្ចាយតនវិបាកចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា និង ឯកគ្គតា ។

*មានចេតសិកប្រកប ៣០*

-អញ្ញសមានាចេតសិក ១០ (វៀរវិតក្កៈ វិចារៈ បីតិ)

-សោភណចេតសិក ២០ (វៀរវិរតិ ៣ អប្បមញ្ញា ២) ។

*ចែកជាខន្ធ*

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ២៨ ជាសង្ខារក្ខន្ធ

-អរូបាវចរវិបាកចិត្ត ជាវិញ្ញាណខន្ធ ។

*ចែកជាធាតុ*

-ចេតសិក ៣០ ជាធម្មធាតុ

-អរូបាវចរវិបាកចិត្ត ជាមនោវិញ្ញាណធាតុ ។

*ចែកជាអាយតន*

-ចេតសិក ៣០ ជាធម្មាយតន

-អុបាវចរវិបាកចិត្ត ជាមនាយតន ។

*ចែកជាសច្ច*

-ចេតសិក ៣០ ជាទុក្ខសច្ច

-អរូបាវចរវិបាកចិត្ត ជាទុក្ខសច្ច ។

## ធម៌អប់រំចិត្ត

ស្ដីអំពី ឧទាននៃព្រះសម្ពុទ្ធ

(ចាកខុទ្ទកនិកាយ ឧទាន បិដកលេខ ៥២ ទំព័រ ៣៥៩)

*យេកេចិ សោកា បរិទេវិតា វា*

*ទុក្ខា ច លោកស្មឹ អនេករូបា*

*បិយំ អដិច្ច ភវន្តិ ឯតេ*

*បិយេ អសន្តេ ន ភវន្តិ ឯតេ ។*

សេចក្ដីសោកក្ដី សេចក្ដីខ្សឹបខ្សួលក្ដី ណាមួយ ឬ សេចក្ដីទុក្ខជាច្រើនយ៉ាង ក្នុងលោកធម៌ទាំងនុ៎ះ រមែងកើតឡើង ព្រោះអាស្រ័យសត្វ និងសង្ខារជាទីស្រលាញ់ កាលបើមិនមាន សត្វ និងសង្ខារជាទីស្រលាញ់ ធម៌ទាំងនុ៎ះក៏រមែងមិនមាន ។

# អរូបាវចរវិបាកចិត្តដួងទី ២

*២.ឧបេក្ខេកគ្គតាសហិតំ វិញ្ញាណញ្ចាយតន- វិបាកចិត្តំ ។*

វិញ្ញាណញ្ចាយតនវិបាកចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា និង ឯកគ្គតា ។

*មានចេតសិកប្រកប ៣០*

-អញ្ញសមានាចេតសិក ១០ (វៀរ វិតក្កៈ វិចារៈ បីតិ)

-សោភណចេតសិក ២០ (វៀរវិរតិ ៣ អប្បមញ្ញា ២) ។

*ចែកជាខន្ធ*

| | |
|---|---|
| -វេទនាចេតសិក | ជាវេទនាខន្ធ |
| -សញ្ញាចេតសិក | ជាសញ្ញាខន្ធ |
| -ចេតសិក ២៨ | ជាសង្ខារខន្ធ |
| -អរូបាវចរវិបាកចិត្ត | ជាវិញ្ញាណក្ខន្ធ ។ |

*ចែកជាធាតុ*

| | |
|---|---|
| -ចេតសិក ៣០ | ជាធម្មធាតុ |
| -អរូបាវចរវិបាកចិត្ត | ជាមនោវិញ្ញាណធាតុ ។ |

*ចែកជាអាយតន*

| | |
|---|---|
| -ចេតសិក ៣០ | ជាធម្មាយតន |
| -អរូបាវចរវិបាកចិត្ត | ជាមនាយតន ។ |

*ចែកជាសច្ច*

-ចេតសិក ៣០ ជាទុក្ខសច្ច

-អរូបាវចរវិបាកចិត្ត ជាទុក្ខសច្ច ។

## ធម៌អប់រំចិត្ត

ស្ដីអំពី ឧទាននៃព្រះសម្ពុទ្ធ

(ចាកខុទ្ទកនិកាយ ឧទាន បិដកលេខ ៥២ ទំព័រ ៣១៣)

*យស្ស មូលំ ឆមា នត្ថិ បណ្ណា នត្ថិ កុតោ លតា*

*តំ ធីរំ ពន្ធនា មុត្តំ កោ តំ និន្ទិតុមរហតិ*

*ទេវាបិ នំ បសំសន្តិ ព្រហ្មុនាបិ បសំសិតោតិ ។*

ឫស គឺអវិជ្ជា និង ផែនដី គឺអាសវៈ មិនមានដល់អរិយបុគ្គលណា ស្លឹកគឺសេចក្ដីស្រើង ក៏មិនមានវល្លិ៍ គឺមានៈនឹងមានមកអំពីណា បុគ្គលណានឹងគួរតិះដៀលនូវអរិយបុគ្គលនោះដែលជាអ្នកប្រាជ្ញផុតចាកបំណងបាន សូម្បីពួកទេវតា ក៏សរសើរបុគ្គលនោះ ទាំងព្រហ្មក៏សរសើរដែរ ។

# អរូបាវចរវិបាកចិត្តដួងទី ៣

## *៣.ឧបេក្ខេកគ្គតាសហិតំ អាកិញ្ចញ្ញាយតនវិបាកចិត្តំ ។*

អាកិញ្ចញ្ញាយតនវិបាកចិត្ត ដែលកើតឡើងប្រកបដោយអង្គឈាន ២ គឺឧបេក្ខា នឹង ឯកគ្គតា ។

### *មានចេតសិកប្រកប ៣០*

-អញ្ញសមានាចេតសិក ១០ (វៀរ វិតក្កៈ វិចារៈ បីតិ)

-សោភណចេតសិក ២០ (វៀរវិរតិ ៣ អប្បមញ្ញា ២) ។

### *ចែកជាខន្ធ*

| | |
|---|---|
| -វេទនាចេតសិក | ជាវេទនាខន្ធ |
| -សញ្ញាចេតសិក | ជាសញ្ញាខន្ធ |
| -ចេតសិក ២៨ | ជាសង្ខារក្ខន្ធ |
| -អរូបាវចរវិបាកចិត្ត | ជាវិញ្ញាណក្ខន្ធ ។ |

### *ចែកជាធាតុ*

| | |
|---|---|
| -ចេតសិក ៣០ | ជាធម្មធាតុ |
| -អរូបាវចរវិបាកចិត្ត | ជាមនោវិញ្ញាណធាតុ ។ |

### *ចែកជាអាយតន*

| | |
|---|---|
| -ចេតសិក ៣០ | ជាធម្មាយតន |
| -អរូបាវចរវិបាកចិត្ត | ជាមនាយតន ។ |

*ចែកជាសច្ច*

-ចេតសិក ៣០ ជាទុក្ខសច្ច

-អរូបាវចរវិបាកចិត្ត ជាទុក្ខសច្ច ។

## ធម៌អប់រំចិត្ត

### ស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ

(ចាកខុទ្ទកនិកាយ ឧទាន បិដកលេខ ៥២ ទំព័រ ២២៧)

*យេ កេចិ ភូតា ភវិស្សន្តិ យេ ចាបិ*

*សព្វេ គមិស្សន្តិ បហាយ ទេហំ*

*តំ សព្វជានិ កុសលោ វិទិត្វា*

*អាតាបិយោ ព្រហ្មចរិយំ ចរេយ្យាតិ ។*

ពួកសត្វណាមួយ ដែលកើតហើយក្តី នឹងកើតក្នុងអនាគតក្តី ពួកសត្វទាំងអស់នោះ នឹងលះបង់នូវរាងកាយទៅកាន់(បរលោក)ដូចគ្នា បណ្ឌិតអ្នកឈ្លាសដឹងច្បាស់ សេចក្តីសាបសូន្យទាំងអស់នោះហើយ គួរជាអ្នកមានព្យាយាមប្រព្រឹត្តព្រហ្មចរិយធម៌ ។

## អរូបាវចរវិបាកចិត្តដួងទី ៤

*៤.ឧបេក្ខេកគ្គតាសហិតំ នេវសញ្ញានាសញ្ញាយតនវិបាកចិត្តំ ។*

នេវសញ្ញានាសញ្ញាយតនវិបាកចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២គឺ ឧបេក្ខា និង ឯកគ្គតា ។

*មានចេតសិកប្រកប ៣០*

-អញ្ញសមានាចេតសិក ១០ (វៀរវិតក្កៈ វិចារៈ បីតិ)
-សោភណចេតសិក ២០ (វៀរ វិរតិ៣ អប្បមញ្ញា២) ។

*ចែកជាខន្ធ*

| | |
|---|---|
| -វេទនាចេតសិក | ជាវេទនាខន្ធ |
| -សញ្ញាចេតសិក | ជាសញ្ញាខន្ធ |
| -ចេតសិក ២៨ | ជាសង្ខារក្ខន្ធ |
| -អរូបាវចរវិបាកចិត្ត | ជាវិញ្ញាណក្ខន្ធ ។ |

*ចែកជាធាតុ*

| | |
|---|---|
| -ចេតសិក ៣០ | ជាធម្មធាតុ |
| -អរូបាវចរវិបាកចិត្ត | ជាមនោវិញ្ញាណធាតុ ។ |

*ចែកជាអាយតន*

| | |
|---|---|
| -ចេតសិក ៣០ | ជាធម្មាយតន |
| -អរូបាវចរវិបាកចិត្ត | ជាមនាយតន ។ |

## ចែកជាសច្ច

-ចេតសិក ៣០ ជាទុក្ខសច្ច

-អរូបាវចរវិបាកចិត្ត ជាទុក្ខសច្ច ។

# ធម៌អប់រំចិត្ត

ស្តីអំពី ឧទាននៃព្រះសម្ពុទ្ធ

(ចាកខុទ្ទកនិកាយ ឧទាន បិដកលេខ ៥២ ទំព័រ ២៦២)

ភិក្ខុមានកាយខ្ជាប់ខ្ជួន មានចិត្តខ្ជាប់ខ្ជួន ទោះដើរ ដេក ឈរ អង្គុយ តែងតម្កល់សតិនុ៎ះ ភិក្ខុនោះគប្បីបានគុណវិសេស មានទីបំផុតខាងដើម លុះបានគុណវិសេស មានទីផុតខាងដើមហើយ ក៏ដល់នូវការមិនជួបប្រទះមច្ចុរាជ ។

# **អរូបាវចរកិរិយាចិត្ត ៤ ដួង**

## *អរូបាវចរកិរិយាចិត្តដួងទី ១*

*១. ឧបេក្ខេកគ្គតាសហិតំ អាកាសានញ្ចាយតនកិរិយាចិត្តំ ។*

អាកាសានញ្ចាយតនកិរិយាចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា និង ឯកគ្គតា ។

*មានចេតសិកប្រកប ៣០*

-អញ្ញសមានាចេតសិក ១០ (វៀរវិតក្កៈ វិចារៈ បីតិ)

-សោភណចេតសិក ២០ (វៀរវិរតិ ៣ អប្បមញ្ញា ២)។

*ចែកជាខន្ធ*

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ២៨ ជាសង្ខារក្ខន្ធ

-អរូបាវចរកិរិយាចិត្ត ជាវិញ្ញាណក្ខន្ធ

*ចែកជាធាតុ*

-ចេតសិក ៣០ ជាធម្មធាតុ

-អរូបាវចរកិរិយាចិត្ត ជាមនោវិញ្ញាណធាតុ ។

*ចែកជាអាយតន*

-ចេតសិក ៣០ ជាធម្មាយតន

-អរូបាវចរកិរិយាចិត្ត ជាមនាយតន ។

## ចែកជាសច្ច

-ចេតសិក ៣០ ជាទុក្ខសច្ច
-អរបាវចរកិរិយាចិត្ត ជាទុក្ខសច្ច ។

# ធម៌អប់រំចិត្ត

## ស្តីអំពី ជនមានចិត្តស្លុងទៅកាន់ព្រះនិព្វាន

(ចាកខុទ្ទកនិកាយ មហានិទ្ទេស បិដកលេខ ៦៦ ទំព័រ ១៦៨)

បណ្ឌិតទាំងឡាយឱ្យទាន មិនមែនឱ្យព្រោះហេតុសេចក្តីសុខនៃឧបធិ ដើម្បីភពថ្មីទេ បណ្ឌិតទាំងនោះឱ្យទានដើម្បីការអស់ទៅនៃឧបធិ មិនដើម្បីភពថ្មីដោយពិត ។ បណ្ឌិតទាំងឡាយចំរើនឈាន មិនមែនព្រោះហេតុ សុខនៃឧបធិដើម្បីភពថ្មីទេ បណ្ឌិតទាំងនោះ ចំរើនឈាន ដើម្បីការអស់ឧបធិ មិនដើម្បីភពថ្មីដោយពិត ។ បណ្ឌិតទាំងនោះ មានចិត្តត្រេកអរស៊ប់ចំពោះការរំលត់ទុក្ខ ទើបឱ្យទាន មានចិត្តទន់ទៅកាន់ព្រះនិព្វាននោះ មានចិត្តចុះស៊ប់ទៅកាន់ព្រះនិព្វាននោះ បណ្ឌិតទាំងនោះ មានព្រះនិព្វានជាទីប្រព្រឹត្តទៅខាងមុខដូចស្ទឹងទាំងឡាយ ដែលហូរទៅកាន់កណ្តាលនៃសាគរ ។

## អរូបាវចរកិរិយាចិត្តដួងទី ២

*២.ឧបេក្ខេកគ្គតាសហិតំ វិញ្ញាណញ្ចាយតន-កិរិយាចិត្តំ។*

វិញ្ញាណញ្ចាយតនកិរិយាចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា និង ឯកគ្គតា ។

*មានចេតសិកប្រកប ៣០*

-អញ្ញសមានាចេតសិក ១០ (វៀរវិតក្កៈ វិចារៈ បីតិ)

-សោភណចេតសិក ២០ (វៀរវិរតិ ៣ អប្បមញ្ញា ២)។

*ចែកជាខន្ធ*

| | |
|---|---|
| -វេទនាចេតសិក | ជាវេទនាខន្ធ |
| -សញ្ញាចេតសិក | ជាសញ្ញាខន្ធ |
| -ចេតសិក ២៨ | ជាសង្ខារក្ខន្ធ |
| -អរូបាវចរកិរិយាចិត្ត | ជាវិញ្ញាណក្ខន្ធ ។ |

*ចែកជាធាតុ*

| | |
|---|---|
| -ចេតសិក ៣០ | ជាធម្មធាតុ |
| -អរូបាវចរកិរិយាចិត្ត | ជាមនោវិញ្ញាណធាតុ ។ |

*ចែកជាអាយតន*

| | |
|---|---|
| -ចេតសិក ៣០ | ជាធម្មាយតន |
| -អរូបាវចរកិរិយាចិត្ត | ជាមនាយតន ។ |

*ចែកជាសច្ច*

-ចេតសិក ៣០ ជាទុក្ខសច្ច

-អរូបាវចរកិរិយាចិត្ត ជាទុក្ខសច្ច ។

# ធម៌អប់រំចិត្ត

## ស្ដីអំពី ពាក្យថា មិនលិចចុះ

(ចាកខុទ្ទកនិកាយ មហានិទ្ទេស បិដកលេខ ៦៦ ទំព័រ ១៥៧)

បុគ្គលដែលត្រូវសរណាមួយមុតហើយ រមែងស្ទុះទៅកាន់ទិសទាំងពួង បុគ្គលដកសរនោះហើយទើបមិន ស្ទុះទៅ មិនលិចចុះ ។

ពាក្យថា មិនលិចចុះ គឺមិនលិចចុះក្នុងអន្លង់គឺកាមមិនលិចចុះក្នុងអន្លង់គឺភព មិនលិចចុះក្នុងអន្លង់គឺទិដ្ឋិមិនលិចចុះ មិនច្រមុជ មិនសំយុងចុះ មិនធ្លាក់ចុះ មិនឈមចុះក្នុងអន្លង់គឺអវិជ្ជា ហេតុនោះព្រះពុទ្ធអង្គទ្រង់ត្រាស់ថា បុគ្គលដកសរនោះហើយ ទើបមិនស្ទុះទៅមិនលិចចុះ ។

# អរូបាវចរកិរិយាចិត្តជួងទី ៣

## *៣.ឧបេក្ខេកគ្គតាសហិតំ អាកិញ្ចញ្ញាយតនកិរិយាចិត្តំ ។*

អាកិញ្ចញ្ញាយតនកិរិយាចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺ ឧបេក្ខា និង ឯកគ្គតា ។

### *មានចេតសិកប្រកប ៣០*

-អញ្ញសមានាចេតសិក ១០ (វៀរវិតក្កៈ វិចារៈ បីតិ)

-សោភណចេតសិក ២០ (វៀរវិរតិ ៣ អប្បមញ្ញា ២)។

### *ចែកជាខន្ធ*

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ២៨ ជាសង្ខារក្ខន្ធ

-អរូបាវចរកិរិយាចិត្ត ជាវិញ្ញាណក្ខន្ធ ។

### *ចែកជាធាតុ*

-ចេតសិក ៣០ ជាធម្មធាតុ

-អរូបាវចរកិរិយាចិត្ត ជាមនោវិញ្ញាណធាតុ ។

### *ចែកជាអាយតន*

-ចេតសិក ៣០ ជាធម្មាយតន ។

-អរូបាវចរកិរិយាចិត្ត ជាមនាយតន។

## វែកជាសច្ច

-ចេតសិក ៣០ ជាទុក្ខសច្ច

-អរូបាវចរកិរិយាចិត្ត ជាទុក្ខសច្ច ។

# ធម៌អប់រំចិត្ត

## ស្ដីអំពីការលូតលាស់ និងការមិនលូតលាស់ក្នុងធម៌វិន័យ

(ចាកខុទ្ទកនិកាយ មហានិទ្ទេស បិដកលេខ ៦៦ ទំព័រ ៨៣)

ពួកកភិក្ខុណា ជាអ្នកកុហក រឹងរូស ពោលពាក្យ អែបអប មានកិលេសដូចស្នែង មានមានះខ្ពស់ឡើង មិនមានចិត្តតាំងមាំ ភិក្ខុទាំងនោះ រមែងមិនលូតលាស់ក្នុងធម៌ ដែលព្រះសម្មាសម្ពុទ្ធត្រាស់ទុកហើយ ឯពួកភិក្ខុណា ជាអ្នកមិនកុហក មិនពោលអែបអប ជាអ្នកប្រាជ្ញ មិនរឹងរូស មានចិត្តតាំងមាំ ភិក្ខុទាំងនោះ រមែងលូតលាស់ក្នុងធម៌ ដែលព្រះសម្មាសម្ពុទ្ធត្រាស់ទុកហើយ ។

## អរូបាវចរកិរិយាចិត្តដួងទី ៤

*៤.ឧបេក្ខេកគ្គតាសហិតំ នេវសញ្ញានាសញ្ញាយតនកិរិយាចិត្តំ ។*

នេវសញ្ញានាសញ្ញាយតនកិរិយាចិត្ត ដែលកើតឡើងព្រមដោយអង្គឈាន ២ គឺឧបេក្ខា និង ឯកគ្គតា ។

*មានចេតសិកប្រកប ៣០*

-អញ្ញសមនាចេតសិក ១០ (វៀរវិតក្កៈ វិចារៈ បីតិ)

-សោភណចេតសិក ២០ (វៀរវិរតិ ៣ អប្បមញ្ញា ២)។

*ចែកជាខន្ធ*

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ២៨ ជាសង្ខារក្ខន្ធ

-អរូបាវចរកិរិយាចិត្ត ជាវិញ្ញាណក្ខន្ធ ។

*ចែកជាធាតុ*

-ចេតសិក ៣០ ជាធម្មធាតុ

-អរូបាវចរកិរិយាចិត្ត ជាមនោវិញ្ញាណធាតុ ។

*ចែកជាអាយតន*

-ចេតសិក ៣០ ជាធម្មាយតន

-អរូបាវចរកិរិយាចិត្ត ជាមនាយតន ។

*ចែកជាសច្ច*

-ចេតសិក ៣០ ជាទុក្ខសច្ច

-អរូបាវចរកិរិយាចិត្ត ជាទុក្ខសច្ច ។

## ធម៌អប់រំចិត្ត

ស្តីអំពី ការយល់របស់បុគ្គលអ្នកមិនសាបសូន្យ

(ចាកខុទ្ទកនិកាយ មហានិទ្ទេស បិដកលេខ ៦៦ ទំព័រ ១៩៥)

សេចក្តីប្រកាន់ក្នុងនាមនិងរូប ដោយសព្វគ្រប់នៃបុគ្គលណាមិនមានទេ បុគ្គលនោះរមែងមិនសោក ព្រោះសត្វ និងសង្ខារដែលមិនមាន បុគ្គលនោះឯងរមែងមិនសាបសូន្យក្នុងលោក ។

ខន្ធណានីមួយ ដែលគួរប្រកាន់ថា នេះរបស់អញ ឬថានេះរបស់បុគ្គលដទៃ នៃបុគ្គលណាមិនមានទេ បុគ្គលនោះកាលមិនបានសេចក្តីប្រកាន់ រមែងមិនសោកថា អញមិនមានរបស់នេះ ដូច្នេះឡើយ ។

# បទសិក្សាទី ១

ស្តីអំពី សិក្ខាបទ ៣ យ៉ាង

(ចាក ខុទ្ទកនិកាយ មហានិទ្ទេស បិដកលេខ ៦៦ ទំព័រ ១៦)

**អធិសីលសិក្ខា តើដូចម្តេច** ?

ភិក្ខុក្នុងសាសនានេះ មានសីល សង្រួមក្នុងបាតិមោក្ខសំវរៈបរិបូណ៌ដោយអាចារៈ និងគោចរៈ ឃើញភ័យក្នុងទោស សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំឡាយ សីលក្ខន្ធតូច សីលក្ខន្ធធំ សីលជាទីពឹង សីលជាខាងដើម ការប្រព្រឹត្ត ការសង្រួម ការរាំង ជាប្រធាន ជាប្រមុខ ដើម្បីបានកុសលធម៌ទាំងឡាយនេះឈ្មោះថា អធិសីលសិក្ខា ។

**អធិចិត្តសិក្ខា តើដូចម្តេច** ?

ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈានប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ចូលកាន់ទុតិយជ្ឈាន ជាធម្មជាតិកើតក្នុងសន្តាននៃខ្លួនប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិ និងសុខៈ ដែលកើតអំពីសមាធិ ។ ព្រោះនឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផង មានស្មារតី ដឹងខ្លួនដោយប្រពៃផង ទទួលសុខដោយនាមកាយផង ព្រះអរិយទាំឡាយ តែងសរសើរបុគ្គល

ដែលបានតតិយជ្ឈាននោះថា បុគ្គលនោះប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានណា ក៏ចូលកាន់តតិយជ្ឈាននោះ ព្រោះលះបង់សុខផង លះបង់ទុក្ខផង ព្រោះវិនាសទៅសោមនស្សនិងទោមនស្សក្នុងកាលមុន ចូលកាន់ចតុត្ថជ្ឈាន ឥតទុក្ខឥតសុខមានសេចក្ដីបរិសុទ្ធិ ដោយឧបេក្ខា និង សតិនេះឈ្មោះថាអធិចិត្តសិក្ខា ។

## អធិប្បញ្ញាសិក្ខា តេដូចម្ដេច ?

ភិក្ខុក្នុងសាសនានេះ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញាប្រព្រឹត្តទៅក្នុងសេចក្ដីចម្រើននិងការវិនាស ជាអ្នកប្រាជ្ញដ៏ប្រសើរ ជាគ្រឿងទំលុះទំលាយ ជាដំណើរទៅដើម្បីការអស់ទុក្ខដោយប្រពៃ ភិក្ខុនោះដឹងច្បាស់ តាមពិតថានេះទុក្ខ ដឹងច្បាស់តាមពិតថា នេះហេតុនាំឱ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះការរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅដើម្បីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា ទាំងនេះជាអាសវៈ ដឹងច្បាស់តាមពិតថា នេះការរលត់អាសវៈនេះឈ្មោះថា អធិប្បញ្ញាសិក្ខា ។

# បទសិក្សាទី ២

## ស្តីអំពីពាក្យថា ព្រះមានព្រះភាគ

(ចាកខុទ្ទកនិកាយ មហានិទ្ទេស បិដកលេខ ៦៦ ទំព័រ ១១)

ពាក្យថា ព្រះមានព្រះភាគ គឺជាពាក្យពោលដោយគោរព ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុបំបាក់បង់នូវរាគៈ ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុបំបាក់បង់នូវទោសៈ ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុបំបាក់បង់នូវមោហៈ ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុបំបាក់បង់នូវមានៈ ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុបំបាក់បង់នូវទិដ្ឋិ ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុបំបាក់បង់នូវចម្រូង ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុបំបាក់បង់នូវកិលេស ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុទ្រង់ចែករំលែកនូវធម្មរតនៈ ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុធ្វើនូវទីបំផុតនៃភពទាំងឡាយ ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុចម្រើនព្រះកាយ ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុចម្រើនសីល ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុចម្រើនចិត្ត ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុចម្រើនបញ្ញា ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុព្រះអង្គទ្រង់គប់រកនូវសេនាសនៈទាំងឡាយដ៏ស្ងាត់ គឺព្រៃតូច និងព្រៃធំ ជាព្រៃមិនមានសំឡេង មិនមានការគឹកកង ជាព្រៃប្រាសចាកខ្យល់កាយនៃជន ជាព្រៃស្ងប់ស្ងាត់ចាក មនុស្សសមគួរដល់ការពួនសម្ងំ ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុព្រះអង្គទ្រង់មានភាគនៃអត្ថរស ធម្មរស វិមុត្តរស អធិសីល អធិចិត្ត អធិប្បញ្ញា ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុព្រះអង្គទ្រង់មានភាគនៃឈាន ៤ អប្បមញ្ញា ៤ អរូបសមាបត្តិ ៤ ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុព្រះអង្គទ្រង់មានភាគនៃវិមោក្ខ ៨ អភិភាយតនៈ ៨ អនុបុព្វវិហារសមាបត្តិ ៩ ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុព្រះអង្គទ្រង់មានភាគសញ្ញាភាវនា ១ កសិណសមាបត្តិ ១០ អានាបាន-ស្សតិសមាធិ អសុភសមាបត្តិ ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុព្រះអង្គទ្រង់មានភាគសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ៍ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ មគ្គដ៏ប្រសើរប្រកប ដោយអង្គ ៨ ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុព្រះអង្គទ្រង់មានភាគនៃតថាគតពលៈ ១០ វេសារជ្ជៈ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ពុទ្ធធម៌ ៦ ។

ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុមិនមែនមាតាដាក់ឱ្យ មិនមែនបិតាដាក់ឱ្យ មិនមែនបងប្អូនប្រុសដាក់ ឱ្យ មិនមែនបងប្អូនស្រីដាក់ឱ្យ មិនមែនពួកមិត្ត អាមាត្យ ដាក់ឱ្យ មិនមែនពួកញាតិសាលោហិតដាក់ឱ្យ មិនមែនពួកសមណព្រាហ្មណ៍ដាក់ឱ្យ មិនមែនពួកទេវតាដាក់ឱ្យ នេះជា

ព្រះញាណកើតក្នុងទីបំផុតនៃវិមោក្ខ របស់ព្រះពុទ្ធទាំងឡាយគ្រប់ព្រះអង្គ បញ្ញាត្តិថា ព្រះមានព្រះភាគនុ៎ះ កើតដោយការធ្វើឱ្យជាក់ច្បាស់ ព្រមទាំងការបានចំពោះនូវសព្វញ្ញុតញ្ញាណទៀបគល់ នៃពោធិព្រឹក្ស ។

# បទសិក្សាទី ៣

## ស្តីអំពី សរ គឺ រាគៈ

(ចាកខុទ្ទកនិកាយ មហានិទ្ទេស បិដកលេខ ៦៦ ទំព័រ ១៤៣)

**សរគឺរាគៈ តើដូចម្តេច** ?

តម្រេក តម្រេកខ្លាំង សេចក្តីស្រើបស្រាល សេចក្តីត្រេកត្រអាល សេចក្តីរីករាយ តម្រេកដែលប្រកបដោយសេចក្តីរីករាយ តម្រេកខ្លាំងនៃចិត្ត អភិជ្ឈា លោភៈ អកុសលមូល ឯណានេះឈ្មោះថា សរ គឺរាគៈ ។

# បទសិក្សាទី ៤

## ស្តីអំពី រតី ទោសៈ

(ចាក ខុទ្ទកនិកាយ មហានិទ្ទេស បិដកលេខ ៦៦ ទំព័រ ១៦៣)

**សរ គឺ ទោសៈ តើដូចម្តេច** ?

គំនុំកើតឡើងថា គេបានប្រព្រឹត្តនូវសេក្តីវិនាសដល់អាត្មាអញ គុំនំកើតឡើងថា គេកំពុងប្រព្រឹត្តនូវសេចក្តីវិនាសដល់អាត្មាអញ គំនុំកើតឡើងថា គេនឹងប្រព្រឹត្តនូវសេចក្តីវិនាសដល់អាត្មាអញ ភាពនៃចិត្តកាច ការញ៉ាំងទឹកភ្នែកឱ្យស្រក់ ភាពនៃចិត្តមិនត្រេកអរនេះ ឈ្មោះថា សរ គឺ ទោសៈ ។

# បទសិក្សាទី ៥

## ស្តីអំពី សរ គឺ មោហៈ

(ចាកខុទ្ទកនិកាយ មហានិទ្ទេស បិដកលេខ ៦៦ ទំព័រ ១៤៣)

**សរ គឺ មោហៈ តើដូចម្តេច**?

ការមិនដឹងទុក្ខ ការមិនដឹងនូវសេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់ទីរំលត់ទុក្ខ ការមិនដឹងទីបំផុតខាងដើម ការមិនដឹងទីបំផុតខាងចុង ការមិនដឹងទីបំផុតខាងដើម និងទីបំផុតខាងចុង ការមិនដឹងក្នុងធម៌ទាំងឡាយ ដែលកើតឡើងអាស្រ័យគ្នានិងគ្នា ព្រោះរបស់នេះជាបច្ច័យ ការមិនឃើញ ការមិនយល់ច្បាស់ ការមិនភ្ញាក់រលឹក ការមិនត្រាស់ដឹង ការមិនចាក់ធ្លុះ ការមិនកាន់យកស៊ប់ ការមិនស្ទង់ចុះស៊ប់ ការសម្លឹងមើលមិនស្មើ ការមិនពិចារណាអំពើមិនជាក់ច្បាស់ ការមិនផ្សរផង់ ភាពនៃសេចក្តីល្ងង់ខ្លៅ សេចក្តីវង្វេង សេចក្តីវង្វេងខ្លាំង សេចក្តីវង្វេងជ្រប់ អវិជ្ជា អន្លង់ គឺអវិជ្ជាយោគៈ គឺអវិជ្ជា អនុស័យគឺអវិជ្ជា បរិយុដ្ឋានគឺអវិជ្ជា គន្លឹះគឺអវិជ្ជា មោហៈ អកុសលមូលឯណា មានសភាពយ៉ាងនេះ នេះឈ្មោះថា សរ គឺ មោហៈ ។

# **បទសិក្សាទី ៦**

## ស្តីអំពី សរគឺ មានៈ

(ចាកខុទ្ទកនិកាយ មហានិទ្ទេស បិដកលេខ ៦៦ ទំព័រ ១៤៤)

**សរ គឺមានៈ តើដូចម្តេច** ?

សេចក្តីប្រកាន់ថា អាត្មាអញជាបុគ្គលប្រសើរ ការប្រកាន់ថា អាត្មាអញជាបុគ្គលស្មើ ការប្រកាន់ថា អាត្មាអញជាបុគ្គលថោកទាប សេចក្តីប្រកាន់ ការប្រកាន់ ភាពនៃសេចក្តីប្រកាន់ ការឆ្មើងឆ្មៃ ការក្រអឺតក្រអោង សភាពដូចទង់ការប្រកាន់ចិត្ត ភាពនៃចិត្តប្រាថ្នាដូចទង់ឯណា មានសភាពយ៉ាងនេះ នេះឈ្មោះថា សរគឺមានៈ ។

# បទសិក្សាទី ៧
## ស្តីអំពី សរ គឺ ទិដ្ឋិ

(ចាកខុទ្ទកនិកាយ មហានិទ្ទេស បិដកលេខ ៦៦ ទំព័រ ១៤៨)

**សរ គឺ ទិដ្ឋិ តើដូចម្តេច** ?

សក្កាយទិដ្ឋិ មានវត្ថុ ២០ មិច្ឆាទិដ្ឋិមានវត្ថុ ១០ អន្តគ្គាហិកទិដ្ឋិមានវត្ថុ ១០ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ការប្រកាន់ គឺទិដ្ឋិ ផ្លូវលំបាកគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ គ្រឿងញាប់ញ័រគឺទិដ្ឋិ សំយោជនៈ គឺទិដ្ឋិ ការកាន់យក ការកាន់មាំ ការប្រកាន់ការស្ទាបអង្អែល ផ្លូវអាក្រក់ គន្លង់ខុស ភាពនៃសេចក្តីខុស ការ ប្រកាន់ភ្លាត់ ការប្រកាន់ឃ្លៀងឃ្លាត ការប្រកាន់ខុស ការប្រកាន់វត្ថុមិនពិតថា ជាវត្ថុពិត ទិដ្ឋិ ៦២ ទាំងប៉ុន្មានមានសភាពយ៉ាងនេះ ឈ្មោះ ថា សរគឺ ទិដ្ឋិ ។

# បទសិក្សាទី ៨

## ស្តីអំពីសរគឺ សេចក្តី សោក

(ចាកខុទ្ទកនិកាយ មហានិទ្ទេស បិដកលេខ ៦៦ ទំព័រ ១៤៥)

**សរគឺ សេចក្តីសោក តើដូចម្តេច** ?

ការសោក អាការសោក ភាពនៃសេចក្តីសោក ការស្ងួតស្ងប់ក្នុង ការស្រពោនក្នុង ការក្តៅក្នុង ការក្តៅរោលរាលខាងក្នុង ការសញ្ជប់សញ្ជឹងនៃចិត្ត ការតូចចិត្តរបស់បុគ្គលដែលត្រូវវិនាសចាកញាតិប៉ះពាល់ត្រូវក្តី ត្រូវវិនាសភោគៈប៉ះ-ពាល់ត្រូវក្តី ត្រូវវិនាសគឺរោគប៉ះពាល់ក្តី ត្រូវវិនាសចាកសីលប៉ះពាល់ត្រូវក្តី ត្រូវវិនាសគឺទិដ្ឋិប៉ះពាល់ក្តី ឬប្រកបដោយវិនាសណាមួយក្តី ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ក្តី នេះឈ្មោះថាសរ គឺ សេចក្តីសោក ។

# បទសិក្សាទី ៩

## ស្តីអំពី សរគឺសេចក្តីសង្ស័យ

(ចាកខុទ្ទកនិកាយ មហានិទ្ទេស បិដកលេខ ៦៦ ទំព័រ ១៤៥)

**សរ គឺសេចក្តីសង្ស័យ តើដូចម្តេច** ?

សេចក្តីសង្ស័យក្នុងទុក្ខ សេចក្តីសង្ស័យក្នុងទុក្ខសមុទយៈ សេចក្តីសង្ស័យក្នុងទុក្ខនិរោធ សេចក្តីសង្ស័យក្នុងទុក្ខនិរោធគាមិនីបដិបទា សេចក្តីសង្ស័យក្នុងទីបំផុតខាងដើម សេចក្តីសង្ស័យក្នុងទីបំផុតខាងចុង សេចក្តីសង្ស័យក្នុងទីបំផុតខាងដើមនិងខាងចុង សេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ដែលកើតឡើងអាស្រ័យគ្នា និងគ្នា ព្រោះរបស់នេះជាបច្ច័យ សេចក្តីសង្ស័យ អាការសង្ស័យ ភាពនៃសេចក្តីសង្ស័យ ការប្រាសចាកសេចក្តីយល់ ការងឿងឆ្ងល់ផ្លូវបែកជាពីរ ការអល់អែក ការកាន់យកនូវចំនែកច្រើនយ៉ាង ការស្ទាក់ស្ទើរ ការអង្អើអង្អែ ការមិនចុះចិត្តស៊ប់ ភាពនៃចិត្តច្រូលច្រាល ការសាំញ៉ាំនៃចិត្តឯណា មានភាពយ៉ាងនេះ នេះឈ្មោះថា សរ គឺសេចក្តីសង្ស័យ ។

## បទសិក្សាទី ១០

### ស្តីអំពី ខន្ធមិនគួរដល់ការត្រេកអរ

(ចាកខុទ្ទកនិកាយ មហានិទ្ទេស បិដកលេខ ៦៦ ទំព័រ ១៧៧)

*បុរាណំ នាភិនន្ទេយ្យ នវេ ខន្តិមកុព្វយេ*

*ហីយមានេ ន សោចេយ្យ អាកស្សំ ន*

*សិតោ សិយាតិ ។*

បុគ្គលមិនគប្បីត្រេកអរ ចំពោះបូរាណខន្ធ (ខន្ធចាស់) មិនគប្បីធ្វើសេចក្តីពេញចិត្ត ក្នុងនវក្ខន្ធ (ខន្ធថ្មី ) មិនគប្បីសោកស្តាយចំពោះវត្ថុកាលវិនាស មិនគប្បីអាស្រ័យសភាវៈជាគ្រឿងទាញមក ។

# សមថកម្មដ្ឋាន ៤០

*ពួកទី ១ កសិណ ១០ គឺ*

(វត្ថុ ឬ របស់ដែលត្រូវយកមកសំឡឹងមើលជាអារម្មណ៍ គឺជាទីតាំងឱ្យចិត្តគិតទៅរក នឹងនាំចិត្តឱ្យមូល ឬថា ស្ងប់មិនរវើរវាយទៅក្នុងអារម្មណ៍ដទៃ ហៅថាកសិណ) ។

១.*បថវីកសិណ* ដី (ទំហំជារាងរង្វង់ពីកែង-ចុងដៃ និងថែម ៤ម្រាមទៀត ។

២.*អាបោកសិណ* ទឹក) ។

៣.*តេជោកសិណ* ភ្លើង ។

៤.*វាយោកសិណ* ខ្យល់ ។

៥.*នីលកសិណ* ពណ៌ខៀវ ។

៦.*បីតកសិណ* ពណ៌លឿង ។

៧.*លោហិតកសិណ* ពណ៌ក្រហម ។

៨.*ឱទាតកសិណ* ពណ៌ស ។

៩.*អាកាសកសិណ* ទីដែនគ្មានអ្វីបិទបាំង, ទីទទេ ឬថា អាកាសដែលសូន្យចាករបស់បិទបាំង ។

១០.*អាលោកកសិណ* ពន្លឺដែលចាំងពីភ្លើងឬថ្ងៃជាដើម ។

## ពួកទី ២ អសុភ (របស់មិនស្អាត) ១០ គឺ

១.*ឧទ្ធុមាតកំ* អសុភហើមប៉ោងឡើង (ខ្មោចមនុស្សឬសត្វងាប់)។

២.*វិនីលកំ* អសុភហើមមានពណ៌ខៀវ ។

៣.*វិបុព្វកំ* អសុភហើមមានខ្ទុះហូរទៅខាងលើខាងក្រោម ។

៤.*វិច្ឆិទ្ទកំ* អសុភដែលគេកាត់ពាក់កណ្តាលខ្លួន ។

៥.*វិក្ខាយិកំ* អសុភដែលសត្វកកេរខាំ មានដំបៅរលួយ ។

៦.*វិក្ខិត្តកំ* អសុភដែលមានដៃនិងជើងដាច់ចេញជាកំណាត់ ។

៧.*ហតវិក្ខិត្តកំ* អសុភដែលគេកាប់មានស្នាមរវាម ។

៨.*លោហិតកំ* អសុភដៃគេប្រហារមានលោហិតប្រលាក់ប្រលុះ។

៩.*បុឡុវកំ* អសុភមានហ្វូងដង្កូវវាហូរចេញចាកទ្វារទាំង ៩ ។

១០.*អដ្ឋិកំ* អសុភដែលមានតែរាងឆ្អឹងរាត់រាយខ្ចាត់ខ្ចាយ ។

# ពួកទី ៣ អនុស្សតិ ១០

១.ពុទ្ធានុស្សតិ រលឹកដល់គុណព្រះពុទ្ធ ។
២.ធម្មានុស្សតិ រលឹកដល់គុណព្រះធម៌ ។
៣.សង្ឃានុស្សតិ រលឹកដល់គុណព្រះសង្ឃ ។
៤.សីលានុស្សតិ រលឹកដល់សីលដែលខ្លួនរក្សា ។
៥.ចាគានុស្សតិ រលឹកដល់អំពើល្អ ដែលខ្លួនបានធ្វើ ព្រោះលះបង់អំពើអាក្រក់បាន ។
៦.ទេវតានុស្សតិ រលឹកដល់ទេវតាហិរិឱត្តប្បៈ ។
៧.មរណានុស្សតិ រលឹកដល់សេចក្តីស្លាប់ ។
៨.ឧបសមានុស្សតិ រលឹកដល់សេចក្តីស្ងប់ ។
៩.កាយគតាសតិ រលឹកដល់អាការៈ ៣២ ក្នុងកាយ ។
១០.អានាបានុស្សតិ រលឹកដល់ដង្ហើមចេញចូល ។

## ពួកទី ៤ ព្រហ្មវិហារធម៌ ៤ គឺ

១.*មេត្តា* រាប់អានទាំងសត្រូវ និងមិនមែនសត្រូវ ។

២.*ករុណា* អាណិតទាំងសត្រូវ និងមិនមែនសត្រូវ ។

៣.*មុទិតា* ការត្រេកអរនឹងគេមានបានទ្រព្យ ទាំងសត្រូវ និងមិនមែនសត្រូវ ។

៤.*ឧបេក្ខា* ការមិនត្រេកអរនឹងគេមានបាន និងមិនសោយសោកចំពោះសត្វដែលរងទុក្ខ គឺព្រងើយកន្តើយ ។

## ពួកទី ៥ បដិកូលសញ្ញា ១

១.*បដិកូលសញ្ញា* ត្រូវពិចារណាបច្ច័យឱ្យទៅជារបស់បដិកូល។

## ពួកទី ៦ ធាតុវវដ្ឋាន ១

១.*ធាតុវវដ្ឋាន* ត្រូវពិចារណាធាតុ ១៨ ឱ្យឃើញច្បាស់ថាជាធាតុពិត ។

## ពួកទី ៧ អរូបជ្ឈាន ៤

១.*អាកាសានញ្ចាយតន* អាកាសទទេ ។

២.*វិញ្ញាណញ្ចាយតន* វិញ្ញាណមិនមានទីបំផុត ។

៣.*អាកិញ្ចញ្ញាយតន* អ្វីៗទទេទាំងអស់ ។

៤.*នេវសញ្ញានាសញ្ញាយតន* មាននៅដោយល្អិត ។

## កម្មដ្ឋាន ៤០ ចែកជា ៣ ប្រភេទ

១.*សប្បាយបភេទ* ប្រភេទនៃការសប្បាយ (គួរដល់ចរិត) ។

២.*ភាវនាបភេទ* ប្រភេទនៃការសម្រើន (ឈាន) ។

៣.*អារម្មណបភេទ* ប្រភេទនៃអារម្មណ៍ (៤០ ណាមួយ) ។

## ១-សប្បាយបភេទ

អ្នកចម្រើនកម្មដ្ឋាន ជាទីសប្បាយតាមចរិត ៦ គឺរាគចរិត ១ ទោសចរិត ១ មោហចរិត ១ សទ្ធាចរិត ១ វិតក្កចរិត ១ ពុទ្ធិចរិត ១ ។

-អប្បមញ្ញា ៤ និង នីលកកសិណ ១ បីតកសិណ ១ លោហិតកសិណ ១ ឱទាតកសិណ ១ ជាទីសប្បាយនៃបុគ្គលទោសចរិត។

-អានាបានុស្សតិ ជាទីសប្បាយនៃបុគ្គលមានមោហចរិត និងវិតក្កចរិត ។

-ពុទ្ធានុស្សតិ ១ ធម្មានុស្សតិ ១ សង្ឃានុស្សតិ ១ សីលានុស្សតិ ១ ចាគានុស្សតិ ១ ទេវានុស្សតិ ១ ជាទីសប្បាយនៃបុគ្គលសទ្ធាចរិត ។

-មរណានុស្សតិ ១ ឧបសមានុស្សតិ ១ បដិកូលសញ្ញា ១ ធាតុវវត្ថាន ១ ជាទីសប្បាយនៃបុគ្គល ពុទ្ធិចរិត ។

-បឋវីកសិណ ១ អាបោកសិណ ១ តេជោកសិណ ១ វាយោកសិណ ១ អលោកកសិណ ១ អាកាសកសិណ ១ និងអរូបជ្ឈាន ៤ ជាទីសប្បាយនៃ បុគ្គលគ្រប់ចរិតទាំងពួង ។

## ២-ភាវនាបភេទ

ភាវនាមាន ៣ប្រការគឺ បរិកម្មភាវនា ១ ឧបចារភាវនា ១ និងអប្បនាភាវនា ១ ។ បរិកម្មភាវនានោះបណ្ឌិតទាំងឡាយតែងបានក្នុងកម្មដ្ឋាន ៤០ ហើយចំពោះ ឧបាចារ

ភាវនា និង អប្បនាភាវនា បណ្ឌិតតែងបានចំពោះក្នុងកម្មដ្ឋាន ដោយកន្លែងមិនជាសាធារណៈ ទៅក្នុងកម្មដ្ឋានទាំងពួងឡើយ ។

កម្មដ្ឋាន ១០ គឺ ពុទ្ធានុស្សតិ ១ ធម្មានុស្សតិ ១ សង្ឃានុស្សតិ ១ សីលានុស្សតិ ១ ចាគានុស្សតិ ១ ទេវតានុស្សតិ ១ មរណានុស្សតិ ១ ឧបសមានុស្សតិ ១ បដិកូលសញ្ញា ១ ធាតុវវត្ថាន ១ កម្មដ្ឋានទាំង ១០ នេះចម្រើនបានត្រឹមតែឧបចារឈានប៉ុណ្ណោះ មិនអាចដល់អប្បនាបានឡើយ ពីព្រោះអារម្មណ៍កម្មដ្ឋាននេះល្អិត សុខុម ជ្រាលជ្រៅណាស់ មិនមានព្រះយោគាវចរណា និង ពិចារណាឱ្យបានសព្វគ្រប់ទេ ។

-កម្មដ្ឋាន ៣ កសិណ ១០ អសុភ ១០ អានាបានស្សតិ ១ កាយគតាសតិ ១ ព្រហ្មវិហារ ៤ និង អរូប ៤ នេះ មានទាំងឧបចារ និងអប្បនា ។

-កសិណ ១០ និង អានាបានស្សតិ ១ ទាំង ១១ នេះ មានអានុភាពច្រើន នាំឱ្យបានសម្រេចរូបឈាន តាំងពីបឋមជ្ឈានរហូតដល់បញ្ចមជ្ឈាន ។

-អសុភ ១០ កាយគតាសតិ ១ ទាំង ១១ នេះនាំឱ្យបានសម្រេច បឋមជ្ឈាន ។

-ព្រហ្មវិហារ ៣ គឺ មេត្តា ១ ករុណា ១ និង មុទិតា ១ នាំឱ្យបានសម្រេចត្រឹមតែ ចតុត្ថជ្ឈាន ។

-ឧបេក្ខាព្រហ្មវិហារ នាំឱ្យបានសម្រេចរូបាវចរ-បញ្ចមជ្ឈាន ។

-អរូបជ្ឈាន ៤ នាំឱ្យបានសម្រេច អរូបជ្ឈានតែម៉្យាង រាប់ចូលក្នុងបញ្ចមជ្ឈាន ។

## ៣-អារម្មណបភេទ

ក្នុងអារម្មណបភេទ មាននិមិត្ត ៣ ប្រការគឺបរិកម្មនិមិត្ត ១ ឧគ្គហនិមិត្ត ១ បដិភាគនិមិត្ត ១ ។ និមិត្ត ២ខាងដើម គឺបរិកម្មនិមិត្ត និង ឧគ្គហនិមិត្តនោះ ព្រះយោគាវចរតែងបានក្នុងកម្មដ្ឋានទាំងពួង ដោយបរិយាយតាមសមគួរ ឯបដិភាគនិមិត្តនោះ មិនមានទូទៅក្នុងកម្មដ្ឋានទាំងពួងទេ បានចំពោះតែកម្មដ្ឋាន ២២ ប៉ុណ្ណោះ គឺកសិណ ១០ អសុភ ១០ កាយគតាសតិ ១ និង អានាបានស្សតិ ១ ។

## ជំនួយសុខភាពផ្លូវចិត្តភាគទី ៤



# ស្ថានីយ៍វិទ្យុ ផ្សព្វផ្សាយព្រះធម៌ព្រះពុទ្ធសាសនា ដែលសំដែងដោយ ខ្ញុំព្រះករុណា_អាត្មាភាព ចាន់ សុជន

| ខេត្ត_ក្រុង | វេលាផ្សាយ | ស្ថានីយ៍វិទ្យុ |
|---|---|---|
| បន្ទាយមានជ័យ | ៥:៣០ ព្រឹក<br>៨:00 ល្ងាច (សៅរ៍_អាទិត្យ)<br>បន្តផ្ទាល់ពីប្រទេស ស្រីលង្កា | FM ៩៩ MHz |
| កំពង់ធំ | ៥:៣០ ព្រឹក | FM ៩៨.៣ MHz |
| ឧត្តរមានជ័យ | ៥:៣០ ព្រឹក | FM ៩០.៥ MHz |

**សព្វទានំ ធម្មទានំ ជិនាតិ**

ធម្មទានឈ្នះអស់ទានទាំងពួង



# អ្វីដែលទៀងពិតប្រាកដគឺការមិនទៀង

សោចន្តិ ជនា មមាយិតេ ន ហិ សន្តិ និច្ចា បរិគ្គហា
វិនាភាវសន្តមេវិទំ ឥតិ ទិស្វា នាគារមាវសេ

ជនទាំងឡាយតែងសោយសោក ព្រោះវត្ថុដែលប្រកាន់ថាជារបស់យើង វត្ថុដែលប្រកាន់ថារបស់ទៀងទាត់មិនមានឡើយ ជីវិតនេះ មានការព្រាត់ប្រាសចាករបស់ដែលមានជាធម្មតា អ្នកប្រាជ្ញលុះឃើញដូច្នេះហើយរមែងមិននៅគ្រប់គ្រងផ្ទះឡើយ។